ក្រសួងអប់រំ យុវជន និង កីឡា

# កំរងលំហាត់អំនានថ្នាក់ទី ៣
# នៃសាលារៀនបឋមសិក្សា

នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ
មហាវិទ្យាល័យគរុកោសល្យ
១៩៩៨

# គណៈកម្មការនិពន្ធ និង រៀបរៀង

| | | | | | |
|---|---|---|---|---|---|
| ១- លោក | ទេស សំអុន | អធិការបឋមសិក្សា | ១១-លោក | លាង ចន្ទី | អធិការបឋមសិក្សា |
| ២- លោកស្រី | សឿ ទេពី | - - | ១២-លោក | រត្ន័ ម៉ៅ | - - |
| ៣- លោកស្រី | ប៊ុន សារ៉ន | - - | ១៣-លោកស្រី | ម៉ក់ ពៅ | - - |
| ៤- លោកស្រី | ទិត សារឿត | - - | ១៤-លោកស្រី | យ៉ង់ ប៉ូលី | - - |
| ៥- លោក | យិន ប៊ុនហុង | - - | ១៥-លោកស្រី | ស៊ិន សុន្ទរី | - - |
| ៦- លោកស្រី | ទេព្វ គីមហេង | - - | ១៦-លោក | លាវ ឌីរ៉ា | - - |
| ៧- លោកស្រី | ឯម ហ៊ា | - - | ១៧-លោក | ជា សុខចំរើន | - - |
| ៨- លោកស្រី | បួយ ប៊ុនថាន | - - | ១៨-លោក | ប៊ុន សារិទ្ធ | - - |
| ៩- លោកស្រី | ហួន ឈុនហុង | - - | ១៩-លោកស្រី | ប៊ូ ប៊ុននី | - - |
| ១០-លោកស្រី | សេក ម៉ារុំ | - - | ២០-លោក | នួន ស៊ីរ៉ាញឿន | - - |

អ្នកជំនាញការបារាំងអមវគ្គបណ្តុះបណ្តាលអធិការបឋមសិក្សា និង មធ្យមសិក្សានៅមហាវិទ្យាល័យគរុកោសល្យ

លោក GUY-ROGER MEITINGER

លោកស្រី ANNE BARBARIT


**សូមថ្លែងអំណរគុណចំពោះការឧបត្ថម្ភរបស់ :**

- **មជ្ឈមណ្ឌលវប្បធម៌បារាំង C C F**
- **អង្គការ PASEC II**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * *

**ក្រសួងអប់រំ យុវជន និង កីឡា**
លេខ : ១៩០៥ អយក.បវ
* * * * *

ភ្នំពេញ,ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩

## ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ជំរាបមក

## លោកប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង

**កម្មវត្ថុ :** ការអនុញ្ញាតអោយប្រើប្រាស់ឯកសារ "កំរងលំហាត់អំនានថ្នាក់ទី ៣ នៃសាលារៀនបឋមសិក្សា" នៅសាលារៀនបឋមសិក្សាក្នុងទូទាំងប្រទេស ។

**យោង :** កំនត់ហេតុនៃអង្គប្រជុំស្តីពីការវាយតំលៃកំរងលំហាត់អំនានថ្នាក់ទី ៣ នៃសាលារៀនបឋមសិក្សា ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៩

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជំរាបលោកប្រធានថា ក្រសួងបានអនុញ្ញាតអោយប្រើប្រាស់ "កំរងលំហាត់អំនានថ្នាក់ទី៣ នៃសាលារៀនបឋមសិក្សា" ដែលតាក់តែងឡើងដោយក្រុមអធិការបឋមសិក្សា ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ រវាងរដ្ឋាភិបាលបារាំង និងរាជរដ្ឋាភិបាលកម្ពុជា សំរាប់ជាគុណប្រយោជន៏ដល់សាលាបឋមសិក្សាក្នុងទូទាំងប្រទេស ។

ឯកសារ "កំរងលំហាត់អំនានថ្នាក់ទី ៣ នៃសាលារៀនបឋមសិក្សា" នេះ ជាឯកសារពិគ្រោះ និងបំពេញបន្ថែមសំរាប់ប្រើប្រាស់អមជាមួយនឹងសៀវភៅភាសាថ្នាក់ទី ៣ សំរាប់គ្រូដែលក្រសួងបានអនុញ្ញាត អោយប្រើប្រាស់រួចហើយ ។

សូមលោកប្រធានបង្កលក្ខណៈ និងជំរុញការប្រើប្រាស់ឯកសារនេះអោយបានលទ្ធផលល្អ ។

**ចំលងជូន :**

- គ្រប់អគ្គនាយកដ្ឋាន
- នាយកដ្ឋាននានាដែលមានការពាក់ព័ន្ធ

"*ដើម្បីជ្រាបជាព័ត៌មាន*"

- កាលប្បវត្តិ
- ឯកសារ-នាយកដ្ឋាន ប.វ

# អារម្ភកថា

មុខវិជ្ជាអំនាន ជាមុខវិជ្ជាមួយសំខាន់បំផុតនៅសាលារៀនបឋមសិក្សា ។ ឆ្លងតាមការសិក្សានៃមុខវិជ្ជានេះ សិស្សអាចពង្រីកបានល្អនូវបញ្ញា ស្មារតីរបស់ខ្លួន ព្រមទាំងអាចមានមូលដ្ឋានចាំបាច់ សំរាប់ការសិក្សាមុខវិជ្ជាផ្សេងៗ ដទៃទៀត ។

ឆ្លើយតបទៅនឹងសារៈសំខាន់នៃមុខវិជ្ជាអំនាននេះ អធិការបឋមសិក្សាមួយក្រុម បានផ្តួចផ្តើមស្រាវជ្រាវ ចងក្រងឯកសារនេះឡើង ឈ្មោះហៅថា "កំរងលំហាត់អំនានថ្នាក់ទី ៣" ក្រោមការជួយឧបត្ថម្ភរបស់មហាវិទ្យាល័យ គរុកោសល្យ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ និង នាយកដ្ឋានស្រាវ- ជ្រាវគរុកោសល្យ ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការរវាងរដ្ឋាភិបាលបារាំង និងរាជរដ្ឋាភិបាលកម្ពុជានិងក្នុងគោលបំនង ធ្វើអោយការបង្រៀន និងការរៀននៅសាលារៀនបឋមសិក្សាកាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់ ។

កំរងលំហាត់អំនានថ្នាក់ទី ៣ នេះ គឺជាឯកសារអមជាមួយសៀវភៅភាសាខ្មែរថ្នាក់ទី ៣ របស់ក្រសួងអប់រំ យុវជន និង កីឡា សំរាប់គ្រូបង្រៀននៅបឋមសិក្សាប្រើប្រាស់ជាឯកសារពិគ្រោះ និងជាឯកសារស្រាវជ្រាវ ដែលអាចអោយគ្រូបង្រៀនជ្រើសរើសយកទៅអនុវត្តបាន ឬ អាចជួយគ្រូបង្រៀនក្នុងការពង្រីកសកម្មភាពអំនានតាមគោលវិធីសិស្សមជ្ឈមណ្ឌល "Child centered = Méthode centrée sur l'enfant" ។

សំរាប់មេរៀនអំនាននីមួយៗ សុទ្ធតែមានលំហាត់ពីរខុសៗគ្នា ដែលគ្រូបង្រៀនអាចយកជាគំរូ ឬ ជាគំនិតដើម្បីតាក់តែងលំហាត់ប្លែកៗថែមទៀត ស្របទៅតាមវត្ថុបំនងរបស់មេរៀន និងទៅតាមសមត្ថភាពរបស់សិស្ស ប្រយោជន៍អោយសិស្សចេះត្រិះរិះពិចារណាដោយខ្លួនឯង និងចេះពិភាក្សាគ្នាតាមក្រុម ។

ឆ្លងតាមការអនុវត្តលំហាត់ទាំងនោះ សិស្សពិតជាអាចអភិវឌ្ឍខ្លួនឯងដោយផ្ទាល់ ពិសេស ចេះអានស្ងាត់ ដែលជាទំលាប់មួយយ៉ាងល្អ និងចាំបាច់បំផុតនៅក្នុងការរស់នៅ ។ អំនានស្ងាត់នេះ គួរតែត្រូវអនុវត្តតាំងពីថ្នាក់ទាបឡើងទៅ ទើបអាចមានប្រសិទ្ធភាព ព្រោះថា តទៅក្នុងជីវភាពប្រចាំថ្ងៃ ការប្រើអំនានស្ងាត់មានអាទិភាពច្រើនជាងអំនានលឺ ដូចជា ការអានស្លាកសញ្ញាផ្សេងៗ អានសារព័ត៌មាន ទស្សនាវដ្តី អានដើម្បីស្រាវជ្រាវ អានប្រលោមលោក ឬ រឿងរ៉ាវប្រវត្តិសាស្ត្រ អានឯកសារប្រលងជាដើម ។ ដូចនេះ អំនានស្ងាត់គឺជាសកម្មភាពតែមួយគត់ ដែលផ្សារភ្ជាប់ទៅនឹងការយល់អត្ថន័យពិតប្រាកដរបស់អត្ថបទ ហើយអាចជាគំនិតក្នុងការបង្កើតសំនេរ ។ រីឯអំនានលឺវិញ ជាអំនានមួយបែបមានប្រយោជន៍ណាស់ដែរ គឺអានសំរាប់អ្នកមិនចេះអក្សរស្តាប់ អានសំរាប់ជូនដំនឹងដល់អ្នកដែលគ្មានអត្ថបទនៅក្នុងដៃ ឬ អានសំរាប់ផ្សព្វផ្សាយព័ត៌មានផ្សេងៗ ។ ដើម្បីហ្វឹកហាត់បំនិននេះ យើងត្រូវត្រៀមសកម្មភាពពិសេសដោយឡែក ។ អោយសិស្សអានលឺ ដើម្បីអាចវាយតំលៃ និងកែលំអ : ការបន្លឺសំលេងអោយត្រូវតាមតួអក្សរ ការលើកដាក់សំលេងទៅតាមប្រភេទផ្សេងៗនៃអត្ថបទ ការគោរពសញ្ញាសំព័ន្ធ ។ល។

ដូចនេះ យើងអាចសន្និដ្ឋានបានថា អំនានទាំងពីរបែប មិនអាចចោលមួយណាបានឡើយ គឺចាំបាច់ត្រូវធ្វើសកម្មភាពអោយបានសមស្របទៅនឹងតួនាទីរបស់អំនានទាំងពីរ ដើម្បីអភិវឌ្ឍបំនិនដោយឡែករបស់សិស្ស និងដើម្បីធ្វើអោយការរៀន និងការបង្រៀនអំនានប្រព្រឹត្តទៅបានលទ្ធផលល្អ ។

ភ្នំពេញ,ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨
គណៈកម្មការនិពន្ធ និង រៀបរៀង

# មាតិការឿង

**ផ្នែកទី ១ :** **លំហាត់**

## ជំពូកទី ១


**មេរៀនទី ១ :** មេសូត្រ "ការរស់នៅស្អាត" ............ ទំព័រ ១
- លំហាត់ទី ១ : ស្វែងកន្សោមពាក្យ ............ ១
- លំហាត់ទី ២ : ភ្ជាប់សំនួរទៅនឹងចំលើយ ............ ១

**មេរៀនទី ២ :** អំនាន "ចំនីអាហារទ្រទ្រង់ជីវិត" ............ ៣
- លំហាត់ទី ១ : Q C M ............ ៣
- លំហាត់ទី ២ : ញែករូបភាពដោយប្រើអត្ថបទ ............ ៤

**មេរៀនទី ៣ :** មេសូត្រ "ផ្ទះមានសិរី" ............ ៥
- លំហាត់ទី ១ : Q C M ............ ៥
- លំហាត់ទី ២ : រកពាក្យក្រៅក្រុម ............ ៦

**មេរៀនទី ៤ :** អំនាន "ក្មេងមានទំលាប់ល្អ" ............ ៧
- លំហាត់ទី ១ : រៀបល្បះអោយត្រូវតាមលំដាប់ឡើងវិញ ............ ៧
- លំហាត់ទី ២ : ជ្រើសរើសចំលើយត្រូវ រឺ ខុស ............ ៨

**មេរៀនទី ៥ :** អំនាន "កន្លែងគួរលេង" ............ ១០
- លំហាត់ទី ១ : បំពេញចន្លោះ ............ ១០
- លំហាត់ទី ២ : ភ្ជាប់ពាក្យក្នុងតារាង ............ ១១

**មេរៀនទី ៦ :** អំនាន "កំនែអផ្សុកនៅពេលទំនេរ" ............ ១២
- លំហាត់ទី ១ : បំពេញចន្លោះ ............ ១២
- លំហាត់ទី ២ : រកកន្សោមពាក្យក្រៅក្រុម ............ ១៣


## ជំពូកទី ២

**មេរៀនទី ១ :** អំនាន " កូនដណ្ដើមមរតកគ្នា " ............................................................................ ១៤

- លំហាត់ទី ១ : រកពាក្យ ខុស បួន ..........................................................................១៤
- លំហាត់ទី ២ : ញែកអត្ថបទពីរដែលដាក់បញ្ចូលគ្នា .......................................................... ១៥

**មេរៀនទី ២ :** អំនាន "គ្រួសារល្អ" ................................................................................. ១៦

- លំហាត់ទី ១ : រកពាក្យក្រៅក្រុមក្នុងអត្ថបទ.................................................................. ១៦
- លំហាត់ទី ២ : ស្រង់កន្សោមពាក្យ...........................................................................១៧

**មេរៀនទី ៣ :** មេសូត្រ "សេចក្ដីសុខក្នុងគ្រួសារ" ............................................................... ១៨

- លំហាត់ទី ១ : បំពេញចន្លោះដោយប្រើឃ្លា .................................................................. ១៨
- លំហាត់ទី ២ : រកពាក្យខុស ៤ ................................................................................ ១៩

**មេរៀនទី ៤ :** អំនាន "គ្រួសារកុសលទៅលេងភ្នំពេញ" ..................................................... ២០

- លំហាត់ទី ១ : រកពាក្យខុស ៥ ................................................................................២០
- លំហាត់ទី ២ : Q C M រកគំនិតសំខាន់របស់អត្ថបទក្នុងចំនោមសំនើទាំង ៥..................... ២១

**មេរៀនទី ៥ :** មេសូត្រ "រួមគ្នាកសាងជាតិ" ........................................................................ ២២

- លំហាត់ទី ១ : រកឃ្លាក្រៅក្រុមក្នុងអត្ថបទ ................................................................... ២២
- លំហាត់ទី ២ : ជ្រើសរើសចំលើយត្រូវ រឺខុស ................................................................. ២៣

**មេរៀនទី ៦ :** អំនាន "ទំនាក់ទំនងល្អរវាងអ្នកជិតខាង" ..................................................... ២៤

- លំហាត់ទី ១ : រកសញ្ញាសំព័ន្ធ ............................................................................... ២៤
- លំហាត់ទី ២ : រកពាក្យក្រៅក្រុម ............................................................................ ២៤

## ជំពូកទី ៣

**មេរៀនទី ១ :** អំនាន "ភ្នំបាណន់" ................................................................................. ២៦

- លំហាត់ទី ១ : បំពេញចន្លោះ .................................................................................. ២៦
- លំហាត់ទី ២ : ជ្រើសរើសចំលើយត្រូវ រឺខុស .................................................................២៧

**មេរៀនទី ២ :** អំនាន "សិប្បកម្មនៅកម្ពុជា" ......................................................................... ២៨

- លំហាត់ទី ១ : ភ្ជាប់ឃ្លា ............................................................................................២៨
- លំហាត់ទី ២ : ជ្រើសរើសចំលើយត្រូវ រឺខុស ................................................................. ២៩

**មេរៀនទី ៣ :** អំនាន "សាមគ្គីភាពនៅក្នុងសហគមន៍" ........ ៣០
- លំហាត់ទី ១ : រកពាក្យក្រៅក្រុមក្នុងអត្ថបទ ........ ៣០
- លំហាត់ទី ២ : រកឃ្លាដែលបាត់ក្នុងអត្ថបទ ........ ៣១

**មេរៀនទី ៤ :** អំនាន "កិត្តិសព្ទលោកតាក្រមង៉ុយ" ........ ៣២
- លំហាត់ទី ១ : រកសញ្ញាសំព័ន្ធ ........ ៣២
- លំហាត់ទី ២ : រកពាក្យខុស ៤ ........ ៣៣

## ជំពូកទី ៤

**មេរៀនទី ១ :** អំនាន "ជីវភាពអ្នកនេសាទ" ........ ៣៤
- លំហាត់ទី ១ : រកពាក្យក្រៅក្រុម ........ ៣៤
- លំហាត់ទី ២ : គូសព្រួញភ្ជាប់ពាក្យក្នុងតារាង ........ ៣៥

**មេរៀនទី ២ :** មេសូត្រ "ត្រូវឧស្សាហ៍ដាំ និងថែដំនាំ " ........ ៣៦
- លំហាត់ទី ១ : រកពាក្យខុស ៤ ........ ៣៦
- លំហាត់ទី ២ : រៀបអត្ថបទពាក្យកាព្យឡើងវិញ ........ ៣៧

**មេរៀនទី ៣ :** អំនាន "មិត្តសំលាញ់ពិសេស" ........ ៣៨
- លំហាត់ទី ១ : ជ្រើសរើសចំលើយត្រូវមួយក្នុងចំនោមសំនើ ២ ........ ៣៨
- លំហាត់ទី ២ : រកឃ្លាក្រៅក្រុមនៅក្នុងអត្ថបទ ........ ៣៩

**មេរៀនទី ៤ :** អំនាន "គីសមុទ្រ និង កង្កែបថ្មក" ........ ៤០
- លំហាត់ទី ១ : ភ្ជាប់ឃ្លាដើម្បីអោយបានជាល្បះ ........ ៤០
- លំហាត់ទី ២ : រកពាក្យដែលជំនួសសព្វនាម ........ ៤១

**មេរៀនទី ៥ :** អំនាន "ផ្លូវគមនាគមន៍" ........ ៤២
- លំហាត់ទី ១ : បំពេញចន្លោះ ........ ៤២
- លំហាត់ទី ២ : Q C M ........ ៤៣

## ផ្នែកទី ២ : ឧទាហរណ៍ព្រឹត្តិបំត្រូគរុកោសល្យ

ការបញ្ចូលលំហាត់អំនានស្វាត់ទៅក្នុងការបង្រៀនអំនានថ្នាក់ទី ៣

មេរៀនទី ១ ជំពូកទី ១ ........................................................................................ ៤៥
មេរៀនទី ២ ជំពូកទី ១ ........................................................................................ ៤៩

# ផ្នែកទី ១

# លំហាត់

## ជំពូកទី ១

## មេរៀនទី ១

## មេសូត្រ ៖ ◘ការរស់នៅស្អាត◘ ស.ស ទំព័រទី ៧

**លំហាត់អំនានស្ងាត់**

ក- លំហាត់ទី ១

ចូរអានអត្ថបទមេសូត្រ ទំព័រទី ៧ សៀវភៅសិស្សដោយស្ងៀមស្ងាត់ ។ ស្រង់កន្សោមពាក្យទាំងឡាយណា ដែលបញ្ជាក់ពីការសំអាតខ្លួនប្រាណដាក់លើក្ដារឆ្នួន ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្ដារខៀនមុនពេលចូលរៀន ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់អំពីសំនួមពរលំហាត់ តើគេអោយអ្នកធ្វើអ្វីខ្លះ ?

(មិនអោយសិស្សអានលំហាត់ឡើងវិញទេ) ។ បើសិស្សមិនយល់ គ្រូត្រូវពន្យល់បន្ថែម ។

៤- អោយសិស្សអានអត្ថបទមេសូត្រក្នុងសៀវភៅដោយស្ងៀមស្ងាត់ ។

៥- ទុកពេលអោយសិស្សធ្វើលំហាត់ ។

៦- អោយសិស្សសរសេរចំលើយលើក្ដារឆ្នួន ។

៧- ធ្វើកំនែរួមនៅលើក្ដារខៀន ។

៨- អោយសិស្សកែកំហុសខ្លួនឯងលើក្ដារឆ្នួនរៀង១ខ្លួន ។

៩- អោយសិស្សអានចំលើយដែលគេបានកែត្រឹមត្រូវនៅលើក្ដារខៀន ។

ចំលើយ : សំអាតកាយា   ដុសក្បាល   លាងដៃ   ដុសធ្មេញ ។

ខ- លំហាត់ទី ២

ចូរស្រង់លេខសំនួរខាងក្រោម ភ្ជាប់ទៅនឹងចំលើយដែលត្រូវគ្នា រួចផ្ទៀងផ្ទាត់ទៅនឹងអត្ថបទ ។ សរសេរចំលើយលើក្ដារឆ្នួន ។

១- មុនទៅសាលារៀនតើគេធ្វើអ្វីខ្លះ ?
២- មុននិងក្រោយពេលហូបអាហារ តើគេធ្វើអ្វីខ្លះ ?
៣- មុនពេលចូលដំនេកតើគេធ្វើអ្វី ?

ក- បោសគ្រែ ពូកក្ដារមុងខ្នើយ ដេញមូស ។
ខ- លាងដៃ ដុសធ្មេញ ។
គ- ងូតទឹកសំអាតខ្លួន ស្លៀកពាក់ ។
ឃ- ធ្វើកិច្ចការដែលគ្រូដាក់អោយ ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្ដារខៀនមុនម៉ោង ។
២- អោយសិស្សអានលំហាត់លើក្ដារខៀនដោយស្ងៀមស្ងាត់ ។
៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ដោយសំដីផ្ទាល់របស់គេ ។ មិនអោយអានលំហាត់ឡើងវិញទេ ។ គ្រូត្រូវពន្យល់បើសិស្សមិនយល់លំហាត់ ។
៤- អោយសិស្សសរសេរចំលើយលើក្ដារឆ្នួនតាមគំរូនេះ :

| | |
|---|---|
| ១ | |
| ២ | |
| ៣ | |

គ្រូគូសតារាងលើក្ដារខៀន សិស្សគូរលើក្ដារឆ្នួន ។
៥- ទុកពេលអោយសិស្សគិតពិចារណាផ្ទួន ។
៦- ធ្វើកំនែរួមលើក្ដារខៀនដោយអោយសិស្សម្នាក់ឡើងមកបំពេញចំលើយក្នុងតារាង រួចអោយសិស្សអានសំនួរ និងចំលើយដែលត្រូវគ្នា ។

ចំលើយ :

| | |
|---|---|
| ១ | គ |
| ២ | ខ |

| ៣ | ក |
|---|---|

*

*          *

## ជំពូកទី ១

## មេរៀនទី ២

## អំណាន : ▫ចំណីអាហារទ្រទ្រង់ជីវិត▫ ស.ស ទំព័រទី ១៥

**លំហាត់អំណានស្ទាត់**

ក- លំហាត់ទី ១

ចូរអានអត្ថបទស.ស ទំព័រទី ១៥ ។

ចូររកចំលើយមួយរឺច្រើន ដោយស្រង់លេខណាមួយ រឺលេខទាំងឡាយណាដែលត្រូវនឹងអត្ថបទ ។ សរសេរ

ចំលើយលើក្តារឆ្នួន ។

ក- កុមារដែលបរិភោគអាហារគ្រប់ប្រភេទ ជាកុមារ :

១- សប្បាយចិត្ត

២- មានការល្បិតលាស់ល្អ

៣- មានជំងឺញឹកញាប់

ខ- នៅក្នុងរូបភាព ក្នុងសៀវភៅសិស្សទំព័រទី 15 ខ្ញុំឃើញ :

១- គោញីមួយ

២- ត្រី

៣- មាន់មួយ

៤- ទឹកដោះគោ

គ- គេចែកចំនីអាហារជា :

១- បួនប្រភេទ

២- ប្រាំប្រភេទ

៣- ពីរប្រភេទ

៤- បីប្រភេទ

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្ដារខៀនមុនម៉ោង ។

២- អោយសិស្សអានអត្ថបទក្នុងសៀវភៅទំព័រទី 15 ដោយស្ងៀមស្ងាត់ដោយមិនអោយអ្នកណាម្នាក់អានលឺជាមុនឡើយ ។

៣- អោយសិស្សអានលំហាត់ដែលសរសេរនៅលើក្ដារខៀនដោយស្ងៀមស្ងាត់ ។

៤- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ តែមិនអោយសិស្សអានលំហាត់ឡើងវិញទេ ។

៥- ពន្យល់សិស្សអំពីរបៀបឆ្លើយនឹងសំនួរ ដោយស្រង់លេខណាមួយ រឺលេខទាំងឡាយណាដែលជាចំលើយត្រូវ ។ ធ្វើលំហាត់ជាឧទាហរណ៍មួយ :

ឧទាហរណ៍ : នៅក្នុងអាហារប្រភេទទី ២ យើងឃើញ :

ក- អង្ករ

ខ- គោ

គ- គ្រួចពោធិ៍សាត់

ចំលើយ : (ក)

៦- ទុកពេលអោយសិស្សម្នាក់ៗធ្វើលំហាត់ ។

៧- ធ្វើកំនែរួមនៅលើក្ដារខៀន ។

សំគាល់ : សំរាប់សំនួរ គ អាចនឹងចាំបាច់អោយសិស្សអានអត្ថបទទាំងមូលដោយស្ងាត់ស្ងៀមឡើងវិញ មុននឹងឆ្លើយ រួចទើបអោយអានលឺដើម្បីធ្វើកំនែ ។

ចំលើយ : ក : ២

ខ : ២ ៣ ៤

គ : ៤

ខ- លំហាត់ទី ២

ចូរអានអត្ថបទសៀវភៅសិស្សទំព័រទី ១៥ រួចញែករូបភាពទៅតាមព័ត៌មានក្នុងអត្ថបទ ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្ដារខៀនមុនម៉ោង ។

២- អោយសិស្សអានលំហាត់នៅលើក្ដារខៀនដោយស្ងៀមស្ងាត់ ។ អោយសិស្សប្រាប់ពី សំនូមពរលំហាត់ តើគេអោយអ្នកធ្វើអ្វី មិនមែនអោយសិស្សអានលំហាត់នេះសាឡើងវិញទេ ប៉ុន្តែត្រូវអោយសិស្សពន្យល់មកយើងវិញ តាមគំនិតដែលគេយល់ ។

៣- អោយសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ ។

៤- ទុកពេលអោយសិស្សដើម្បីឆ្លើយនឹងសំនួរ ( សិស្សអាចគូរតិចៗលើរូបភាព) ។

៥- ធ្វើកំនែរួមដោយផ្ដើមចេញពីរូបភាព ។

<u>ចំលើយ</u> :



**<u>ជំពូកទី ១</u>**

**<u>មេរៀនទី ៣</u>**

**<u>មេសូត្រ</u> : ¤ផ្ទះស្អាតមានសិរី¤** ស.ស ទំព័រទី ២៣

**<u>លំហាត់អំនានស្ងាត់</u>**

ក- <u>លំហាត់ទី ១</u>

ចូរជ្រើសរើសចំលើយខាងក្រោមដែលជាគំនិតសំខាន់នៃវគ្គទី ១ និងវគ្គទី ២ នៃអត្ថបទ មេសូត្រទំព័រទី ២៣ ។ សរសេរចំលើយលើក្ដារឆ្នួនដោយចំលងតែលេខនៃវគ្គ និងអក្សរនៅខាងមុខ គំនិតសំខាន់ណាដែល សមស្រប ។

ក- ការសំអាតទីធ្លាជុំវិញផ្ទះ

ខ- ការសំអាតទីធ្លាសាលារៀន

គ- ការសំអាតផ្ទះសំបែង

**<u>លំនាំនៃការបង្រៀន</u>**

១- ចំលងលំហាត់ដាក់លើក្ដារខៀនមុនម៉ោង ។

២- អោយសិស្សអានអត្ថបទមេសូត្រលើក្ដារខៀនឹក្នុងសៀវភៅដោយស្ងៀមស្ងាត់ ។

៣- សួរសិស្ស ¤តើអត្ថបទមេសូត្រនេះចែកជាប៉ុន្មានវគ្គ?¤ ។

¤តើវគ្គទី ១ ពីណាដល់ណា ?¤ ¤តើវគ្គទី ២ ពីណាដល់ណា?¤

៤- អោយសិស្សអានលំហាត់ដែលគ្រូបានចំលងលើក្ដារខៀនដោយស្ងៀមស្ងាត់ ។

៥- សួរសិស្ស ◘តើលំហាត់នេះ គេចង់អោយអ្នកធ្វើអ្វី?◘ អោយសិស្ស ២ រឺ ៣ នាក់ពន្យល់មកវិញ ។

បើសិស្សមិនយល់ គ្រូជួយពន្យល់បន្ថែម ។

៦- ពន្យល់របៀបសរសេរចំលើយលើក្តារឆ្នួន ( បើសិនជាចាំបាច់)

ឧទាហរណ៍ : វគ្គទី ១ $\prod$ គ

អោយសិស្សសរសេរចំលើយលើក្តារឆ្នួន ។

៧- យកចំលើយសិស្ស ២នាក់មកបង្ហាញអោយសិស្សឯទៀតពិនិត្យមើលនិងជ្រើសរើសចំលើយត្រឹមត្រូវ ។

៨- អោយសិស្សអះអាងលើចំលើយដែលគេយល់ថាត្រឹមត្រូវ ។

( ឧទាហរណ៍ : វគ្គទី ១ គេនិយាយអំពីការសំអាតផ្ទះសំបែង ព្រោះមានការសំអាតផ្ទះបាយ បង្គន់ ។ល។ )

៩- ធ្វើសំយោគ រួចលុបឃ្លាដែលមិនត្រឹមត្រូវលើក្តារខៀនចោល ។

១០- អោយសិស្សកែកំហុសរៀង១ខ្លួនលើក្តារឆ្នួន ។

ចំលើយ : វគ្គទី ១ $\prod$ គ

វគ្គទី ២ $\prod$ ក

- គ្រូ រឺសិស្សសូត្រមេសូត្រ អោយសិស្សទាំងអស់ស្តាប់ដោយស្ងៀមស្ងាត់ ។

| |
|---|
| ខ- លំហាត់ទី ២ |
| ចូរអានបញ្ជីកន្សោមពាក្យខាងក្រោម រួចជ្រើសរើសកន្សោមពាក្យក្រៅក្រុមមួយ ។ |
| លំនៅស្ថាន បន្ទប់គេង បន្ទប់ទឹក ដុសធ្មេញ ផ្ទះបាយ បង្គន់ បន្ទប់ទទួលភ្ញៀវ។ |
| ចំលងពាក្យនោះដាក់លើក្តារឆ្នួន ។ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀនមុនម៉ោង ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា តើលំហាត់នេះគេចង់អោយអ្នកធ្វើអ្វីខ្លះ ? ( អោយសិស្សឡើងពន្យល់មកវិញ) ។ គ្រូវពន្យល់បន្ថែម បើសិស្សមិនទាន់យល់ ។ បើសិស្សមិនអាចឆ្លើយបានទៀត គ្រូត្រូវអោយឧទាហរណ៍ដូចជា :

ឆ្មា ឆ្កែ សេះ ពពែ ជ្រូក មាន់ ក្របី ចៀម ។

ចំលើយ : មាន់ ជាពាក្យក្រៅក្រុម ព្រោះជាសត្វមានជើងពីរ រីឯពាក្យឯទៀត សុទ្ធតែជាសត្វជើងបួន ។

៤- អោយសិស្សសរសេរពាក្យនោះលើក្តារឆ្នួន ។

៥- ជ្រើសរើសចំលើយសិស្ស ២ នាក់ ខុសគ្នា លើកបង្ហាញសិស្សឯទៀតដើម្បីអោយពួកគេជ្រើសរើសចំលើយត្រឹមត្រូវ ។

៦- អោយសិស្សទាំង ២ នាក់នេះធ្វើអំនះអំនាងលើចំលើយរបស់ខ្លួន ។

៧- ធ្វើការបូកសរុបយកចំលើយត្រឹមត្រូវ ។

៨- អោយសិស្សម្នាក់ឡើងគូសជុំវិញពាក្យក្រៅក្រុមលើក្តារខៀន ។

ចំលើយ : ដុសធ្មេញ

បញ្ជាក់ : (ពាក្យទាំងអស់សំគាល់ទីកន្លែង ឯពាក្យដុសធ្មេញគឺជាសកម្មភាព) ។

*

* *

## ជំពូកទី ១

## មេរៀនទី ៤

## អំនាន : ▫ក្មេងមានចំលាប់ល្អ▫ ស.ស ទំព័រទី ៣១

**លំហាត់អំនានស្ទាត់**

| | |
|---|---|
| ក- លំហាត់ទី ១<br>ចូរអានបំនែកអត្ថបទទាំងនេះ រួចរៀបលេខតាមលំដាប់គំនិតអោយបានជាអត្ថបទសន្ទនា ដែលមានន័យគ្រប់គ្រាន់ដោយគិតដល់សញ្ញាសំព័ន្ធ ។ សរសេរលេខនៃបំនែកទាំងនោះ ដាក់លើក្តារឆ្នួន ។ | |
| ១ | ពិសីឆ្លើយថា ▫ស្អែកនេះ ខ្ញុំត្រូវរៀនភាសាខ្មែរ គណិតវិទ្យានិងវិទ្យាសាស្ត្រអនុវត្ត▫ ។ |
| ២ | ▫ តើប្អូនកំពុងរៀនអ្វី ? ▫ ។ ពិនឆ្លើយថា ▫ ខ្ញុំកំពុងរំលឹកមេរៀនសីលធម៌ |
| ៣ | ថ្ងៃស្អែក ខ្ញុំត្រូវរៀនសីលធម៌ ! ▫ ។ បងស្រីវាថា ▫ ប្អូនឧស្សាហ៍រៀនយ៉ាងនេះ បងសប្បាយចិត្តណាស់ ! ▫ ។ បងស្រីពិនងាកមកសួរពិសីវិញម្តង ។ |
| ៤ | នៅយប់មួយ ពិសី និង ពិនកំពុងរំលឹកមេរៀន ។ ពេលនោះ បងស្រីវាចូលមក ហើយសួរពិនថា : |
| ៥ | ▫ ពិសី ! តើស្អែកប្អូនរៀនអ្វីខ្លះ ? ▫ ។ |
| ៦ | បងសរសើរប្អូនទាំងពីរថា ▫ប្អូនៗចេះរំលឹកមេរៀនបានត្រឹមត្រូវណាស់ ! ព្រោះថ្ងៃស្អែក លោកគ្រូ រឺអ្នកគ្រូ ប្អូនៗនឹងសួរអំពីមេរៀនចាស់ ▫ ។ |

| | |
|---|---|
| | ពិន និងពិសីរីករាយណាស់ ព្រោះវាបានទទួលការសរសើរពីបងវា ។ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្ដារខៀនមុនម៉ោង ( បើមានលទ្ធភាពគួរសរសេរលំហាត់នេះលើផ្ទាំងក្រដាសធំ ) ។

២- អោយសិស្សអានលំហាត់លើក្ដារខៀន ( អំនានស្ងាត់ ) តែមិនត្រូវអោយសិស្សអានអត្ថបទក្នុងសៀវភៅសិស្សជាមុនទេ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ។

៤- មុននឹងអោយសិស្សធ្វើលំហាត់គ្រូត្រូវបញ្ជាក់ថា ៖

- តើឃ្លានីមួយៗត្រូវបញ្ចប់ដោយសញ្ញាអ្វី ?
- ចំពោះឃ្លាសំនួរ តើគេត្រូវប្រើសញ្ញាអ្វី ?
- ចំពោះឃ្លាដែលជាពាក្យសំដីរបស់តួអង្គ តើត្រូវចាប់ផ្ដើមនិងបញ្ចប់ដោយសញ្ញាអ្វី ?

៥- ប្រាប់ឃ្លាផ្ដើមអត្ថបទជាមុន ( ឃ្លាលេខ ៤ ) ។ អោយសិស្សសរសេរលេខ ៤ លើក្ដារឆ្នួន ។

៦- ទុកពេលអោយសិស្សធ្វើលំហាត់ជាក្រុម ( ២ ទៅ ៣ នាក់ ) ដោយអោយសិស្សសរសេរចំលើយជាលេខលើក្ដារឆ្នួន ។

៧- គ្រូ និងសិស្សធ្វើកំនែរួមលើក្ដារខៀន ។ អោយសិស្សម្នាក់ រឺ ២ នាក់អានអត្ថបទក្នុងសៀវភៅទំព័រទី ៣១ ដើម្បីផ្ទៀងផ្ទាត់ចំលើយខាងលើ ។

<u>ចំលើយ</u> : ៤ ២ ៣ ៥ ១ ៦

ខ- <u>លំហាត់ទី ២</u>

ចូរអានអត្ថបទ «ក្មេងមានទំលាប់ល្អ» ទំព័រទី ៣១ នៃសៀវភៅភាសាខ្មែរដោយស្ងៀមស្ងាត់ ។ ចូរគូសសញ្ញា 4 ចំពោះសំនើត្រូវ និងគូសសញ្ញា 6 ចំពោះសំនើខុស ក្នុងតារាងខាងក្រោមអោយស្របទៅតាមខ្លឹមសារអត្ថបទ ។

| | | ត្រូវ | ខុស |
|---|---|---|---|
| ១ | ថ្ងៃស្អែកពិនត្រូវរៀនមេសូត្រ ។ | | |
| ២ | ពិនកំពុងរំលឹកមេរៀនសីលធម៌ ។ | | |
| ៣ | ថ្ងៃស្អែកនេះពិសីត្រូវរៀនភូមិវិទ្យា ។ | | |
| ៤ | ពិន និងពិសីត្រូវបងស្រីបន្ទោស ។ | | |
| ៥ | ពិន និងពិសីរីករាយណាស់ដោយបានបងស្រីសរសើរ ។ | | |
| ៦ | ថ្ងៃស្អែកពិសីត្រូវរៀនភាសាខ្មែរ គណិតវិទ្យានិងវិទ្យាសាស្ត្រអនុវត្ត ។ | | |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់ក្ដារខៀនមុនម៉ោង ( បើមានលទ្ធភាពគួរសរសេរលំហាត់នេះ លើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ។

៤- អោយសិស្សចំលងតារាងដូចខាងក្រោមដាក់លើក្ដារឆ្នួនដោយមិនបាច់ចំលងល្បះឡើយ ។

| | ត្រូវ | ខុស |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |
| ៤ | | |
| ៥ | | |
| ៦ | | |

បើសិស្សខ្លះមិនយល់ គ្រូពន្យល់សិស្សអំពីរបៀបធ្វើដោយអោយឧទាហរណ៍ដូចខាងក្រោម ▫

ឧទាហរណ៍ :

| | ត្រូវ | ខុស |
|---|---|---|
| ១ | | 6 |
| ២ | 4 | |

៥- ទុកពេលសំរាប់សិស្សម្នាក់ៗធ្វើលំហាត់ ។

៦- ធ្វើកំនែរួមដោយអោយសិស្សឡើងគូសសញ្ញា 4 រឺ 6 នៅក្នុងតារាងលើក្ដារខៀន និងសួរសិស្សថា : ហេតុអ្វីបានជាល្បះនេះឬ្សនថាត្រូវ រឺខុស ( អោយសិស្សបង្ហាញហេតុផលអំពីចំលើយរបស់ខ្លួន) ។

៧- អោយសិស្ស ២ នាក់ អានល្បះឡើងវិញ ( អំនានលឺ) គឺអានតែល្បះត្រូវ ។

ចំលើយ ▫

| | ត្រូវ | ខុស |
|---|---|---|
| ១ | | 6 |
| ២ | 4 | |

| | | |
|---|---|---|
| ៣ | | 6 |
| ៤ | | 6 |
| ៥ | 4 | |
| ៦ | 4 | |

*

*                    *

**ជំពូកទី ១**

**មេរៀនទី ៥**

**អំណាន : ❑កន្លែងគួរលេង❑**        ស.ស ទំព័រទី ៣៩

**លំហាត់អំណានស្ទាត់**

ក- លំហាត់ទី ១

ចូរជ្រើសរើសកន្សោមពាក្យខាងក្រោមមកបំពេញចន្លោះអត្ថបទនេះ ❑

រត់ ចូលរៀន លេងល្បែង និយាយថា ឈរលេង ចេញលេង អភ័យទោស បំនង ។

កន្លែងគួរលេង

នៅពេល..............សំ និងតារានាំគ្នាគប់វង់ នៅទីធ្លាខាងមុខថ្នាក់ ។ ដោយអចេតនា មេគប់ក៏ជ្រុលទៅប៉ះជើងនារី ដែលកំពុង......................នៅខាងមុខថ្នាក់រៀន ។ នារីឈឺជើងយ៉ាងខ្លាំង ។ សំ និង តារាក៏រត់មកជិតនារីរួច ................ ❑សូមនារីអភ័យទោស ! យើងគ្មាន .................. នឹងគប់ឯងទេ❑ ។ នារីតបថា ❑មិនជាអ្វីទេ! តែខ្ញុំយល់ថា អ្នកមិនគួរ..................បែបនេះ នៅកន្លែងនេះទេ ។ ម្យ៉ាងទៀត វាបណ្តាលអោយសំលៀកបំពាក់ និងខ្លួនប្រាណ អ្នកកខ្វក់ ហើយប៉ះពាល់សុវត្ថិភាពខ្លួនឯងនិងអ្នកដទៃផងដែរ❑ ។

សំ និងតារាធ្វើខុសដោយអចេតនាមែន តែសំដីក្រើនរំលឹករបស់នារីធ្វើអោយសំ និង តារាអៀនខ្មាស និងមានវិប្បដិសារីយ៉ាងខ្លាំង ។ ពួកគេអរគុណនារីចំពោះការ.....................និង ពាក្យដាស់តឿនដ៏ល្អនោះ ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់នៅលើក្តារខៀនមុនម៉ោង បើមានលទ្ធភាពគ្រូអាចសរសេរលើផ្ទាំង ក្រដាសធំ ។

២- អោយសិស្សអានលំហាត់លើក្តារខៀនដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីសំនួមពរលំហាត់ តើគេអោយអ្នកធ្វើអ្វី ( មិនមែនអោយអាន លំហាត់ឡើងវិញទេ) ។

៤- អោយសិស្សអានល្បះទី ១ នៃអត្ថបទដោយស្ងៀមស្ងាត់ រួចអោយសិស្សសរសេរពាក្យ ដែលត្រូវបំពេញចន្លោះនោះដាក់ក្តារឆ្នួន ។

៥- ធ្វើកំនែរួមម្តងមួយល្បះៗ រួចអោយសិស្សម្នាក់មកសរសេរបំពេញចន្លោះនៅក្តារខៀន ម្តងមួយចន្លោះៗ ។

៦- ក្រោយពេលបំពេញចប់ត្រូវអោយសិស្សម្នាក់ រឺ ២នាក់ អានអត្ថបទក្នុងសៀវភៅទំព័រទី ៣៩ ដើម្បីផ្ទៀងផ្ទាត់នឹងលំហាត់ខាងលើដែលកែរួច ។

ចំលើយ : ចេញលេង ឈរលេង និយាយថា បំនង លេងល្បែង អភ័យទោស ។

ខ- លំហាត់ទី ២

ចូរអានកន្សោមពាក្យខាងក្រោម រួចជ្រើសរើសយកកន្សោមពាក្យមួយ ក្នុងជួរឈរនីមួយៗមកផ្គុំអោយបានជាល្បះពីរនៃអត្ថបទ ( សៀវភៅសិស្សទំព័រទី ៣៩ ) ។ ចំលង ចំលើយដាក់ក្នុងសៀវភៅរបស់អ្នក ។

| | | | | | | |
|---|---|---|---|---|---|---|
| អ្នក | ក្រើន រំលឹក | ពេលវេលា | បែបដូច | សំ | ដៃ | ទេ |
| ទំពារ | ព្រៃឈើ | លេង ល្បែង | ធ្វើអោយ | ឈើដៃ | ទីកន្លែងនេះ | អៀនខ្មាស |
| សំដី | មិនគួរ | របស់នារី | បែបនេះ | នៅ | និងតារា | ជ្រុលហួស |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀនមុនម៉ោងបង្រៀន (បើមានលទ្ធភាពគ្រូអាចសរសេរ លើផ្ទាំងក្រដាសធំបិទនៅក្តារខៀន) ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ។

៤- អោយសិស្សធ្វើលំហាត់ដែលជាឧទាហរណ៍ងាយៗជាមុនសិន ដើម្បីអោយសិស្សអាចធ្វើ លំហាត់នេះបាន ។

ឧទាហរណ៍ ▪

| | | |
|---|---|---|
| ធីតា | ចំការ | ស្ទូចត្រី |
| គោរព | ទៅវិញ | នំ |

| | | |
|---|---|---|
| ទន្លេ | ចង់ទៅ | រស្មេល |

ចំលើយ :  ធីតាចង់ទៅស្ទូចត្រី ។

៥- ត្រូវទុកពេលអោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៦- អោយសិស្សសរសេរល្បះចំលើយដែលរកឃើញក្នុងសៀវភៅរីលើក្រដាសព្រាង ។

៧- អោយសិស្សបើកសៀវភៅហើយផ្ទៀងផ្ទាត់ចំលើយដែលមាននៅក្នុងអត្ថបទ ។

៨- ធ្វើកំនែរួមនៅក្តារខៀនដោយអោយសិស្សម្នាក់ឡើងមកគូសខ្វែងពីក្រោមពាក្យទាំងឡាយ ដែលជាពាក្យក្នុងល្បះទី ១ ។

| | | | | | | |
|---|---|---|---|---|---|---|
| អ្នក<br>5 | ក្រើន រំលឹក | ពេលវេលា | បែបដូច | សំ | ដៃ | ទេ<br>5 |
| ទំពារ | ព្រៃឈើ | លេងល្បែង<br>5 | ធ្វើអោយ | ឈើដៃ | ទីកន្លែងនេះ<br>5 | អៀនខ្មាស |
| សំដី | មិនគួរ<br>5 | របស់នារី | បែបនេះ<br>5 | នៅ<br>5 | និងតារា | ជ្រុលហួស |

- អោយសិស្សចំលងល្បះទី ១ នេះពីក្រោមលំហាត់ដើម្បីអោយសិស្សឯទៀតបានឃើញចំលើយ ។

ចំលើយល្បះទី ១ :  អ្នកមិនគួរលេងល្បែងបែបនេះនៅកន្លែងនេះទេ ។

- គ្រូអាចហៅសិស្ស ២ រឺ ៣ នាក់អានល្បះនេះ ។

- អោយសិស្សម្នាក់ទៀតឡើងមកគូសជុំវិញពាក្យទាំងឡាយណាដែលជាល្បះទី ២ ។ ធ្វើដូចគ្នាចំពោះល្បះទី ២ ។

ចំលើយល្បះទី ២ :  សំដីក្រើនរំលឹករបស់នារីធ្វើអោយសំ និងតារាអៀនខ្មាស ។

*

*          *

## ជំពូកទី ១

## មេរៀនទី ៦

**អំណាន : ◘កំនែអផ្សុកនៅពេលទំនេរ◘** ស.ស ទំព័រទី ៤៧

**លំហាត់អំណានស្ទាត់**

ក- លំហាត់ទី ១

ចូរជ្រើសរើសពាក្យ រឹកន្សោមពាក្យខាងក្រោមមកបំពេញចន្លោះក្នុងអត្ថបទ ◘ កំសាន្ត អផ្សុក ទូរទស្សន៍ ខុសគ្នា ផ្ទះ ព័តិមាន ទំនេរ ។ ចំលងពាក្យ រឹកន្សោមពាក្យនោះដាក់លើក្តារឆ្នួន ។

កំនែអផ្សុកនៅពេលទំនេរ ជាមធ្យោបាយកាត់បន្ថយការនឿយហត់និងធ្វើអោយសុខភាព បានល្អប្រសើរឡើងវិញ ។ កំនែកំសាន្តរបស់មនុស្សម្នាក់ៗ....................ទៅតាមចំនង់ចំនៀលចិត្ត និងលទ្ធភាពរៀងៗខ្លួន ។ អ្នកខ្លះ ចូលចិត្តទៅទស្សនាកេរដំនែលវប្បធម៌ជាតិ ទេសភាពធម្មជាតិល្អស្រស់ និងកន្លែងមានខ្យល់អាកាសល្អបរិសុទ្ធ ។ អ្នកខ្លះចូលចិត្តទស្សនា សិល្បៈ នៅតាមរោងមហោស្រព រឺស្តាប់វិទ្យុនៅក្នុងផ្ទះ ។ អ្នកខ្លះទៀតច្រើនយកពេល ............ ទៅធ្វើការងារបន្ទាប់បន្សំនៅផ្ទះ ដូចជាថែសួនច្បារ សំអាតផ្ទះសំបែង រឺធ្វើហត្ថកម្មផ្សេងៗ ។ ឯអ្នកមិនចូលចិត្តភាពអ៊ូអរច្រើននៅ............ហើយអានសៀវភៅរឿង សារព័តិមាន រឺទស្សនាវដ្តី ដើម្បីស្វែងយល់............ ផ្សេងៗ ។

| |
|---|
| សកម្មភាពទាំងអស់នោះ មានលក្ខណៈខុសប្លែកពីគ្នាពិតមែន តែវាផ្តល់ភាពសប្បាយរីករាយនិងបំបាត់ការ ................ បានដូចគ្នា ។ |

លំនាំនៃការបង្រៀន

១- ចំលងលំហាត់ដាក់លើក្តារខៀនមុនម៉ោងបង្រៀន (បើមានលទ្ធភាពគ្រូអាចសរសេរលើផ្ទាំងក្រដាសធំបិទនៅក្តារខៀន) ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ និងមិនអោយសិស្សបើកសៀវភៅពុម្ពអានឡើយ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ។

៤- អោយសិស្សសរសេរចំលើយលើក្តារឆ្នួន ។

៥- ទុកពេលអោយសិស្សធ្វើលំហាត់ ។

៦- ធ្វើកំនែរួមម្តងមួយពាក្យៗលើក្តារខៀនរហូតដល់ចប់ ។

៧- អោយសិស្សអានអត្ថបទដែលបំពេញរួច ។

ចំលើយ : ខុសគ្នា ទំនេរ ផ្ទះ ព័ត៌មាន អផ្សុក ។

| |
|---|
| **ខ- លំហាត់ទី ២** |
| ចូរជ្រើសរើសយកសកម្មភាពមួយ ក្នុងបណ្តាសកម្មភាពទាំងឡាយខាងក្រោមនេះ ដែលពុំមាននៅក្នុងអត្ថ- បទទំព័រទី ៤៧ ។ ចំលងសកម្មភាពនោះដាក់លើក្តារឆ្នួន ។ |
| ទស្សនាសិល្បៈ អានសៀវភៅ ស្តាប់វិទ្យុ ស្ទូចត្រី ថៃសួនច្បារ ស្វែងយល់ព័ត៌មាន សំអាត ផ្ទះសំបែង ធ្វើការហត្ថកម្ម ។ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀនមុនម៉ោង ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីសំនួមពរលំហាត់ "តើគេអោយអ្នកធ្វើអ្វី ?" ។

៤- អោយសិស្សអានអត្ថបទទំព័រទី ៤៧ សៀវភៅសិស្សដោយស្ងៀមស្ងាត់ ។

៥- ទុកពេលអោយសិស្សធ្វើលំហាត់ ។

៦- អោយសិស្សសរសេរចំលើយលើក្តារឆ្នួន ។

៧- ធ្វើកំនែរួមលើក្តារខៀននិងអោយសិស្សផ្ទៀងផ្ទាត់ចំលើយក្នុងអត្ថបទ ។

៨- បើសិនជាសិស្សឆ្លើយខុស គ្រូត្រូវយកចំលើយខុសនោះមកបង្ហាញសិស្សឯទៀត រួចសួរសិស្សទាំងនោះថា

សកម្មភាពនេះមាននៅក្នុងអត្ថបទរឺទេ ? នៅបន្ទាត់ទីប៉ុន្មាន ?

៩- អោយសិស្សធ្វើការអះអាងលើចំលើយរបស់ខ្លួន ។

ចំលើយ :  ស្វ័យត្រៃ

*

*  *

## ជំពូកទី ២

## មេរៀនទី ១

## អំនាន : ¤កូនជណ្ដើមមរតកគ្នា¤ ស.ស ទំព័រទី ៥៥

**លំហាត់អំនានស្ងាត់**

ក- លំហាត់ទី ១

ចូរអានអត្ថបទខាងក្រោមនិងរកអោយឃើញពាក្យខុសចំនួន ៤ ពាក្យ ។ ស្រង់ពាក្យទាំងនោះ ដាក់ក្នុងសៀវភៅ រួចធ្វើកំនែពាក្យទាំងនោះអោយបានត្រឹមត្រូវ ។

កូនដណ្ដើមមរតកគ្នា

មានរឿងដំនាលថា កាលពីព្រេងនាយ មានសេដ្ឋីម្នាក់ មានកូនប្រុសបីនាក់ ។ កូនប្រុសច្បង និងកូនប្រុសបន្ទាប់ បានរៀបការប្រពន្ធ ហើយបែកទៅនៅផ្ទះផ្សេង ។ ចំនែកកូនប្រុសពៅ រស់នៅជាមួយឪពុក ។ ក្រោយមកឪពុកឈឺធ្ងន់ ។ កូនពៅខិតខំបំរើ និង ថែរក្សាឪពុកណាស់ តែដោយជំងឺចាស់ជរា សេដ្ឋីក៏ទទួលមរណភាពទៅ ។

បន្ទាប់ពីធ្វើបុណ្យសប់ឪពុករួច កូន២ជចេកគ្នាអំពីការចែកកេរមរតក តែពុំដាច់ស្រេចសោះ ។ ពួកគេនាំគ្នាប្ដឹងទៅចៅក្រម ដើម្បីកាត់ក្ដី តែចៅក្រមកាត់ពុំបាន ព្រោះកូនទាំងបីពុំសុកចិត្ត ។ គាត់ក៏នាំបុរសទាំងបីនោះ ទៅគាល់ព្រះមហាក្សត្រ ។ ទ្រង់សំរេចអោយកូនបងទាំងពីរនាក់ ទទួលកេរមរតកមួយចំនែក២ស្មើគ្នា ឯកូនពៅត្រូវ

បានពីរចំនែក ព្រោះកូនឬទ្ធិបាននៅថែរក្សាឪពុក រហូតដល់គាត់លាចាកលោក ។

**<u>លំនាំនៃការបង្រៀន</u>**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានអត្ថបទនៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ។ មិនមែនអោយអានលំហាត់ឡើងវិញឡើយ ។

៤- ទុកពេលអោយសិស្សបានធ្វើលំហាត់ ។

៥- ធ្វើកំនែរួមលើក្តារខៀនដោយអោយសិស្ស ២ នាក់ឡើងមកគូសពាក្យខុសម្នាក់ ២ ពាក្យ ។ អោយសិស្សឯទៀតផ្ទៀងផ្ទាត់នៅលើសៀវភៅរបស់ខ្លួន ។ សិស្សសរសេរពាក្យត្រូវនៅលើក្តារខៀនជំនួសពាក្យខុស ។

៦- អោយសិស្សដែលសរសេរខុស កែតំរូវកំហុសខ្លួននៅក្នុងសៀវភៅ ។

<u>ចំលើយ</u> : ព្រេងនាយ សព ជជែក សុខចិត្ត ។

ខ- <u>លំហាត់ទី ២</u>

ចូរអានផ្នែកទាំងឡាយរបស់អត្ថបទពីរដែលដាក់បញ្ចូលគ្នាខាងក្រោម ÷

ក- ស្រង់លេខទាំងឡាយណាដែលជាផ្នែករបស់អត្ថបទទី ១ ។

ខ- ស្រង់លេខទាំងឡាយណាដែលជាផ្នែករបស់អត្ថបទទី ២ ។

១- មានរឿងដំនាលថា កាលពីព្រេងនាយ មានសេដ្ឋីម្នាក់មានកូនប្រុសបីនាក់ ។

២- កូនប្រុសច្បងនិងកូនប្រុសបន្ទាប់បានរៀបការប្រពន្ធ

៣- កាលនោះមានខ្លាចាស់មួយដើរស្វែងរកអាហារ ។

៤- ហើយបែកទៅនៅផ្ទះផ្សេង។ ចំនែកកូនប្រុសពៅរស់នៅជាមួយឪពុក ។

៥- វាបានទៅជួបសត្វគីង្គក់មួយកំពុងលោតផ្លោត១ ។ ក្នុងពេលនោះ

៦- កូនពៅខិតខំបំរើឪពុករាល់ថ្ងៃ តែដោយជរា សេដ្ឋីក៏

៧- ខ្លាបបួលគីង្គក់លោតរំលងព្រែក ។

៨- ដោយដឹងពីកលមាយាខ្លា គីង្គក់ក៏យល់ព្រម ។

៩- ទទួលមរណភាពទៅ។ ក្រោយធ្វើបុណ្យសពឪពុករួច កូន១ជជែកគ្នា

១០- នៅទីបំផុតគីង្គក់ក៏បានទទួលជ័យជំនះលើខ្លា ។

១១- អំពីការចែកកេរមរតក តែពុំដាច់ស្រេចសោះ ។

១២- ពួកគេនាំគ្នាប្តឹងទៅចៅក្រម ។

**<u>លំនាំនៃការបង្រៀន</u>**

១- ចំលងលំហាត់ដាក់លើក្ដារខៀន ( បើមានលទ្ធភាពគួរសរសេរលំហាត់នេះលើផ្ទាំង ក្រដាសដែលអាចកាត់តបាន ដើម្បីងាយស្រួលក្នុងការផ្ទៀងផ្ទាត់) ។
២- អោយសិស្សអានលំហាត់ទាំងមូលដោយស្ងៀមស្ងាត់
ដោយរកអោយឃើញផ្នែកទាំងឡាយនៃអត្ថបទនីមួយៗ។
៣- ចែកសិស្សជាក្រុមតូចៗមួយក្រុម ២ នាក់ ហើយអោយសិស្សតាមក្រុមពិភាក្សាគ្នាជ្រើសរើសចំលើយ ។
៤- អោយក្រុមនីមួយៗសរសេរលេខដែលជាចំលើយនៃអត្ថបទទី ១ លើក្ដារឆ្នួន រួចលើកបង្ហាញគ្រូ ។
៥- ធ្វើកំនែរួមអត្ថបទទី ១ ។
K សំគាល់ : បើគ្រូប្រើអត្ថបទដែលអាចកាត់តបាន គួរហៅសិស្សអោយបំបែកអត្ថបទទាំងពីរអោយដាច់ចេញពីគ្នា រួចអោយសិស្សអានជាខាងក្រោយ ។
៦- សរុបចំលើយត្រឹមត្រូវ រួចអោយសិស្សម្នាក់អានអត្ថបទទី ១ សិស្សម្នាក់ទៀតអានអត្ថបទទី ២ ។

ចំលើយ : អត្ថបទទី ១ : ១ ២ ៤ ៦ ៩ ១១ ១២
អត្ថបទទី ២ : ៣ ៥ ៧ ៨ ១០

* *
*

## ជំពូកទី ២

## មេរៀនទី ២

**អំនាន : ¤គ្រួសារល្អ¤** ស.ស ទំព័រទី ៦៣

**លំហាត់អំនានស្ងាត់**

ក- លំហាត់ទី ១

ចូរអានអត្ថបទខាងក្រោមដោយស្ងៀមស្ងាត់ រួចរកអោយឃើញពាក្យ ៤ ដែលលើស និងគ្មានន័យនៅក្នុង អត្ថបទនេះ ។ ចំលើយសរសេរលើក្ដារឆ្នួន ។

ទំនាក់ទំនងល្អនៅក្នុងគ្រួសារ នាំអោយគ្រួសាររីករាយជានិច្ច ។

ម្ដាយឪពុកជាអ្នកមានគុណកុមារា ។ លោកមានភារកិច្ចធ្ងន់ធ្ងរណាស់នៅក្នុងគ្រួសារ ។ លោកចិញ្ចឹមថែរក្សាទំហំនិងថែបំប៉នសុខភាពកូនជានិច្ច ដើម្បីអោយកូនរស់នៅបានល្អ ។ លោកទាំងពីរស៊ូទ្រាំលំបាក ដើម្បីអោយកូនសិក្សា អនិច្ចកម្មស្វែងរកចំនេះវិជ្ជា សំរាប់ជាមធ្យោបាយចិញ្ចឹមជីវិត ។ ម្យ៉ាងទៀតលោកបានផ្ដល់ឱកាសអោយកូនបានសន្ទូចកំសាន្តសប្បាយ និងចូលរួមសកម្មភាពជាមួយនឹងកុមារដទៃ ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់លើក្តារខៀន  រឺបើមានលទ្ធភាពគួរសរសេរលើក្រដាសផ្ទាំងធំ ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សពន្យល់ពីអ្វីដែលគេត្រូវធ្វើ ÷ តើលំហាត់នេះគេអោយអ្នកធ្វើអ្វី ?

（បើសិស្សមិនយល់  គ្រូត្រូវពន្យល់បន្ថែម）។

៤- ទុកពេលអោយសិស្សធ្វើលំហាត់ ។

៥- អោយសិស្សសរសេរចំលើយលើក្តារឆ្នួន ។

៦- ធ្វើកំនែរួមលើក្តារខៀន ។ អោយសិស្សម្នាក់ឡើងមកគូសជុំវិញពាក្យលើសទី ១ ដែលគេបានរកឃើញ ។ អោយសិស្សនោះអានឈ្មោះដែលគេបានដកពាក្យលើសនោះចេញ ។ សួរសមូហភាពថ្នាក់ថា ឈ្មោះនេះមានន័យគ្រប់គ្រាន់ រឺស្តាប់បានហើយរឺនៅ ? បន្ទាប់ពីបាន ចំលើយពីសិស្សក្នុងថ្នាក់ រួចហើយ អោយសិស្សលុបចោលពាក្យលើសនៅក្តារខៀន ។ ធ្វើ ដូចគ្នាចំពោះពាក្យលើសទី  ២  ទី ៣   និង   ទី ៤ ។

ចំលើយ :        កុមារា    ទំហំ    អនិច្ចកម្ម    សន្ទូច ។

| |
|---|
| ខ- លំហាត់ទី ២<br>ចូរអានស្ងាត់អត្ថបទអំនាន ■គ្រួសារល្អ■ នៅទំព័រទី ៦៣ ។ ស្រង់ពាក្យ និង កន្សោមពាក្យទាំងឡាយណាដែលមានន័យបញ្ជាក់ថាជា ■ឪពុកម្តាយ■ ក្នុងអត្ថបទនេះ។ សរសេរពាក្យទាំងនោះក្នុងសៀវភៅរបស់អ្នក ។ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់លើក្តារខៀន ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- សួរសិស្សថា ■តើលំហាត់នេះគេចង់អោយអ្នកធ្វើអ្វីខ្លះ ?■  អោយសិស្សឆ្លើយដោយការយល់របស់គេ តែមិនអោយអានលំហាត់ឡើងវិញទេ ។

៤- អោយសិស្សអានអត្ថបទក្នុងសៀវភៅសិស្សទំព័រទី ៦៣ ដោយស្ងៀមស្ងាត់ ។

៥- អោយសិស្សម្នាក់ៗ សរសេរចំលើយទាំងអស់ដែលខ្លួនរកឃើញដាក់ក្នុងសៀវភៅ

（ពុំចាំបាច់អោយសិស្សបិទសៀវភៅពុម្ពទេ）។

៦- អោយសិស្សអានចំលើយ និងធ្វើអំនះអំនាងលើចំលើយរបស់ខ្លួន   បើសិនជាចាំបាច់ ។

ឧទាហរណ៍ :     ហេតុអ្វីបានជាអ្នកជ្រើសរើសពាក្យ ◘ លោក ◘ ?

ព្រោះពាក្យ ◘លោក◘ ក្នុងអត្ថបទនេះមានន័យបញ្ជាក់ថាជា ◘ឪពុកម្តាយ◘ ។ ពេលសិស្សកំពុងអានចំលើយរបស់គេ គ្រូសរសេរចំលើយរបស់សិស្សនោះលើក្តារខៀន (ទាំងចំលើយខុស និង ត្រូវ) ។

៧- ធ្វើកំនែរួមនៅលើក្តារខៀន ។

៨- បូកសរុប និងទុកតែចំលើយដែលត្រឹមត្រូវនៅលើក្តារខៀន ។

៩- អោយសិស្សកែកំហុសរៀង១ខ្លួនក្នុងសៀវភៅ ។

ចំលើយ : ពាក្យនិងកន្សោមពាក្យដែលមានន័យបញ្ជាក់ថាជា ◘ឪពុកម្តាយ◘ ក្នុងអត្ថបទ នេះមាន ◘ អ្នកមានគុណ   លោក   លោកទាំងពីរ   មាតាបិតា ។

*

*          *

**ជំពូកទី ២**

**មេរៀនទី ៣**

**មេសូត្រ : ◘សេចក្តីសុខក្នុងគ្រួសារ◘** ស.ស ទំព័រទី ៧១

**លំហាត់អំនានស្ទាត់**

ក- លំហាត់ទី ១

ចូរអានស្ទាត់អត្ថបទកំណាព្យនេះ ដែលត្រូវគេដកយកឃ្លាបីទៅដាក់នៅពីខាងក្រោម ◘

| | |
|---|---|
| ១- យាយតាស្រលាញ់ថ្នាក់ថ្នមចៅ | ឃើញឆ្កួងលោកហៅមកទន្ទ្រាន |
| ២- សំដីផ្អែមល្ហែមគ្រប់ជំហាន | ........................................ |
| ៣- បងស្រលាញ់ប្អូនអស់ពីពោះ | មិនដែលទ្រគោះទោះវាចា |
| ៤- ...................................... | ខុសត្រូវយ៉ាងណាត្រាប្រនី ។ |
| ៥- ប្អូនត្រូវគោរពស្រលាញ់បង | កុំបីសៅម៉ងព្រោះសំដី |

៦- ធ្ងន់ស្រាលតិចតួចកុំកើតក្តី ......................................

ចូររកទីតាំងនៃឃ្លាទាំងបី ។ សរសេរចំលើយនៅក្នុងក្រដាសព្រាងដោយចំលងឃ្លាទាំងនេះ រួចហើយដាក់លេខបន្ទាត់ដែលត្រូវបំពេញនៅពីមុខឃ្លាទាំងនោះ ។

- លើសខ្វះមិនគុំក្នុងចិន្តា
- ឈ្នះចាញ់គ្មានអ្វីចំនេញទេ ។
- មិនវាយបំពានលើកាយា ។

**<u>លំនាំនៃការបង្រៀន</u>**

១- ចំលងលំហាត់ដាក់លើក្តារខៀនមុនម៉ោង ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ។

៤- អោយសិស្សធ្វើលំហាត់លើក្រដាសព្រាង ។

៥- ធ្វើកំនែរួមលើក្តារខៀនដោយអោយសិស្សម្នាក់ឡើងសរសេរចំលើយជាលេខនៅមុខល្បះទាំង ៣ ។

<u>ចំលើយ</u>៖ ៤- លើសខ្វះមិនគុំក្នុងចិន្តា

៦- ឈ្នះចាញ់គ្មានអ្វីចំនេញទេ ។

២- មិនវាយបំពានលើកាយា ។

គ្រូសរសេរបំពេញអត្ថបទចន្លោះដែលមាននៅលើក្តារខៀនស្រាប់ រួចអោយសិស្សអាន ។

ខ- <u>លំហាត់ទី ២</u>

ចូរអានស្ងាត់អត្ថបទកំនាព្យខាងក្រោម ។ រកពាក្យខុសចំនួន ៤ ពាក្យ ។ ស្រង់ពាក្យទាំងនោះដាក់លើក្តារ ឆ្នួន និងធ្វើកំនែពាក្យទាំងនោះផង ។

- ម៉ែពុកនឿយហត់ចិញ្ចឹមបុត្រ　　ទឹកចិត្តបរិសុទ្ធនឹងកូនភ្ងា
  អោយកូនសិក្សាយកវិជ្ជា　　ចំនេះនានាទុកជាស្ពាន់ ។
- បងស្រឡាញ់ប្អូនអស់ពីពស់　　មានដែលទ្រគោះទោះវាចា
  លើសខ្វះមិនគុំក្នុងចិន្តា　　ខុសត្រូវយ៉ាងណាត្រាប្រនី ។
- ប្អូនត្រូវគោរពស្រលាញ់បង　　កុំបីសៅម៉ងព្រោះសំដី
  ធ្ងន់ស្រាលតិចតួចកុំកើតស្រី　　ឈ្នះចាញ់គ្មានអ្វីចំនេញទេ ។

**<u>លំនាំនៃការបង្រៀន</u>**

១- ចំលងលំហាត់ដាក់លើក្តារខៀន ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។
៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ប៉ុន្តែមិនមែនអោយសិស្សអានលំហាត់ខាងលើមកវិញទេ គឺគ្រាន់តែប្រាប់
ពីរបៀបធ្វើលំហាត់ ។
៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ ។
៥- ធ្វើកំនែរួមលើក្តារខៀនដោយហៅសិស្សម្នាក់អោយគូសពីក្រោមពាក្យខុស រួចកែពាក្យនោះអោយបានត្រឹមត្រូវ ។ សិស្សឯទៀតកែតំរូវក្នុងសៀវភៅរបស់ខ្លួន ។

<u>ចំលើយ</u> :

| ពាក្យខុស | | ពាក្យត្រូវ |
|---|---|---|
| ស្ពាន់ | Π | ស្ពាន |
| ពស់ | Π | ពោះ |
| មាន | Π | មិន |
| ស្រី | Π | ក្តី |

*

*　　　　*

**<u>ជំពូកទី ២</u>**

**<u>មេរៀនទី ៤</u>**

**<u>អំនាន</u> : ¤គ្រួសារកុសលនៅលេងក្រុងភ្នំពេញ¤** ស.ស ទំព័រទី ៧៩

**<u>លំហាត់អំនានស្ងាត់</u>**

ក- <u>លំហាត់ទី ១</u>

ចូរអានអត្ថបទខាងក្រោមដោយស្ងៀមស្ងាត់ ។ រកពាក្យដែលសរសេរខុសទាំង ៥ ពាក្យ ហើយស្រង់កំហុសទាំងនោះដាក់លើក្តារឆ្នួនរឺក្រដាសព្រាង រួចធ្វើកំនែពាក្យទាំងនោះផង ។

នៅបុណ្យអុំទូកឆ្នាំមុន គ្រួសារកុសលបានទៅលេងក្រុងភ្នំពេញ ។

ព្រលឹមឡើង ពួកគេធ្វើដំនើរដោយរត់យន្តក្រុង ពីខុដុង្គមកភ្នំពេញ តាមផ្លូវជាតិលេខ ៥ ។ មកដល់ផ្សារធំថ្មី ពួកគេចុះពីរត់យន្តក្រុង រួចជិះត្រីចក្រយានទៅផ្ទះសំណាង នៅឯផ្សារកណ្តាល ។ តាមផ្លូវកុសលលាន់មាត់ថា

◘ពុក ! នៅទីក្រុងមានមនុស្សច្រើនណាស់ !◘ ។ ប្អូនស្រីកុសលពោលថា ◘នៅទីក្រុងភ្នំពេញសប្បាយណាស់ ! ផ្លូវ ថ្នល់ស្អាត និងមានផេះលក់ទំនិញល្អៗ ហើយច្រើនសេកស្កះ◘ ។ ឪពុកកុសលក៏និយាយប្រាប់កូនៗថា ◘នេះមកពី ប្រទេសយើងគ្មានសង្គ្រាម ទើបយើងមានការរីកចំរើនយ៉ាងនេះ◘ ។ បន្តិចមក ត្រីចក្រយានបានទៅដល់ផ្ទះសំ-ណាង ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀនរឺលើក្រដាសធំ ( បើមានលទ្ធភាព) មុនម៉ោងបង្រៀន ។

២- អោយសិស្សអានលំហាត់ខាងលើដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីសំនួមពរលំហាត់ តើគេអោយអ្នកធ្វើអ្វី ? មិនអោយសិស្សអានលំហាត់មកវិញទេ ។

៤- ទុកពេលអោយសិស្សធ្វើលំហាត់ ។

៥- អោយសិស្សបង្ហាញចំលើយ រួចធ្វើកំនែរួមនៅលើក្តារខៀន ។

៦- ផ្ទៀងផ្ទាត់ចំលើយជាមួយអត្ថបទក្នុងសៀវភៅសិស្ស ទំព័រ ៧៩ ។

ចំលើយ :

| ពាក្យខុស | ពាក្យត្រូវ |
|---|---|
| ឆ្នាំ | ឆ្នាំ |
| រត់យន្ត . រត់យន្ត | រថយន្ត |
| ផេះ | ផ្ទះ |
| សេកស្កះ | ស្អេកស្កះ |

ខ- លំហាត់ទី ២

ចូរអានអត្ថបទស.ស ទំព័រ ៧៩ ដោយស្ងៀមស្ងាត់ ។ ក្នុងបណ្តាសំនើទាំង ៥ ខាងក្រោមនេះ ចូរជ្រើសរើស សំនើដែលមាន ន័យត្រូវនឹងអត្ថបទ ។ សរសេរលេខ សំនើទាំងនោះដាក់លើក្តារឆ្នួន ។

អត្ថបទនេះនិយាយអំពី :

១- ទិដ្ឋភាពនៅទីក្រុងភ្នំពេញ

២- ទឹកចិត្តសប្បាយរីករាយរបស់អ្នកដំនើរ

៣- ការស្រលាញ់រាប់អានគ្នា

៤- ការធ្វើដំនើរតាមយន្តហោះ

៥- ការទៅមើលបុណ្យអុំទូក

**លំនាំនៃការបង្រៀន**

១- សរសេរលំហាត់លើក្តារខៀន រឺបើមានលទ្ធភាពសរសេរលើក្រដាសធំមុនម៉ោង ។

២- អោយសិស្សអានលំហាត់ ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីសំនួមពរលំហាត់ថា ◘លំហាត់នេះ គេអោយអ្នកធ្វើអ្វី ?◘ ដោយសំដីសិស្សផ្ទាល់ មិនអោយអានលំហាត់ឡើងវិញឡើយ ។

៤- ទុកពេលអោយសិស្សធ្វើលំហាត់ ។

៥- ធ្វើកំនែរួមនៅលើក្តារខៀន ដោយផ្ទៀងផ្ទាត់ជាមួយអត្ថបទ ក្នុងស.ស. ទំព័រ ៧៩ ។

<u>ចំលើយ</u> : ល្បះទី ១ ២ ៣ ៥

*

* *

**<u>ជំពូកទី ២</u>**

**<u>មេរៀនទី ៥</u>**

**<u>មេសូត្រ</u> : ◘រួមគ្នាកសាងជាតិ◘** ស.ស ទំព័រទី ៨៧

**<u>លំហាត់អំនានស្ងាត់</u>**

ក- <u>លំហាត់ទី ១</u>

មេសូត្រខាងក្រោមនេះ មានល្បះមួយដែលលើស និងមានន័យខុសពីអត្ថបទ។ ចូររកល្បះនោះ និងសរសេរ ចំលើយជាលេខលើក្តារឆ្នួន ។

១ ម៉ែពុកស្រលាញ់បុត្រ ចិត្តបរិសុទ្ធមានមេត្តា

ប្រឹងប្រែងប្រកបការ មិនវាចាទោះនឿយប្រាណ ។

| | | |
|---|---|---|
| ២ | ធម្មជាតិទឹកត្រជាក់<br>ទីស្ថានព្រៃព្រឹក្សា | ជាទីស្នាក់នៃមច្ឆា<br>ជាជំរកនៃសព្វសត្វ ។ |
| ៣ | កូនត្រូវខំសិក្សា<br>ចំនេះទាំងប៉ុន្មាន | ទើបគ្រួសារបានថ្កើងថ្កាន<br>ប្រើប្រាស់បានតាមប្រាថ្នា ។ |
| ៤ | កុំរើសអើងការងារ<br>ស្មោះស្ម័គ្រជួយរដ្ឋា | កុំខ្ជិលខ្ជានឹងកិច្ចការ<br>ជាតិខេមរាមានកេរ្តិ៍ឈ្មោះ ។ |

**លំនាំនៃការបង្រៀន**

១- សរសេរលំហាត់ខាងលើ ដាក់លើក្ដារខៀនមុនម៉ោងបង្រៀន ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីសំនួមពរលំហាត់ ◘តើគេអោយអ្នកធ្វើអ្វី ?◘ មិនមែនអោយអានលំហាត់ឡើងវិញឡើយ ។

* សំគាល់ : ពេលធ្វើលំហាត់នេះ មិនអនុញ្ញាតអោយសិស្សបើកសៀវភៅពុម្ពអានឡើយ ។

៤- ទុកពេលអោយសិស្សធ្វើលំហាត់ ។

៥- អោយសិស្សបើកសៀវភៅទំព័រទី ៨៧ អានដើម្បីផ្ទៀងផ្ទាត់ ។

៦- ធ្វើកំនែរួមនៅលើក្ដារខៀន ដោយអោយសិស្សម្នាក់លុបល្បះដែលខុសចោល ។

ចំលើយ : ល្បះលេខ ២ ។

ខ- លំហាត់ទី ២

ចូរអានមេសូត្រក្នុងសស.ទំព័រទី ៨៧ ដោយស្ងៀមស្ងាត់ ។ ធ្វើលំហាត់ខាងក្រោម ដោយគូសក្នុងប្រអប់នូវសញ្ញា ◘5◘ ចំពោះឃ្លាដែលគ្មាននៅក្នុងមេសូត្រ និងគូសសញ្ញា ◘3◘ ចំពោះឃ្លាដែលមាននៅក្នុងមេសូត្រ ។

| | | |
|---|---|---|
| ១ | ធ្វើអ្វីត្រូវគិតខ្លួនឯង មិនខ្លាចក្រែងពីកិត្តិយស | |
| ២ | កុំរើសអើងការងារ កុំខ្ជិលខ្ជានឹងកិច្ចការ | |
| ៣ | រួមគ្នាទើបខ្មែររស់ បានខ្ពង់ខ្ពស់ក្នុងសកល | |
| ៤ | បែកបាក់ខ្មែរមិនរស់ កិត្តិយសខ្មែរអាប់អោន | |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ។

៤- ទុកពេលអោយសិស្សធ្វើលំហាត់ជាបុគ្គល ដោយអោយសរសេរចំលើយតាមគំរូ :

| | |
|---|---|
| ១ | |
| ២ | |
| ៣ | |
| ៤ | |

៥- ធ្វើកំនែរួមនៅលើក្តារខៀន ។ អោយសិស្ស ២ នាក់ ឡើងមកគូសសញ្ញា 5 រឺ 3 នៅក្នុងប្រអប់លើក្តារខៀន និងធ្វើអំនះអំនាងលើចំលើយរបស់ខ្លួន ។

ចំលើយ :

| | |
|---|---|
| ១ | 5 |
| ២ | 3 |
| ៣ | 3 |
| ៤ | 5 |

*

*          *

**ជំពូកទី ២**

**មេរៀនទី ៦**

**អំនាន : ◘ ជំនាក់ជំនួលល្អរវាងអ្នកជិតខាង ◘** ស.ស ទំព័រទី ៩៥

**លំហាត់អំនានស្ងាត់**

ក- លំហាត់ទី ១

ចូរអានអត្ថបទខាងក្រោម ។ ចំលងអត្ថបទនេះឡើងវិញដោយដាក់សញ្ញាសំព័ន្ធដូចជា ◘ដកឃ្លា◘ ◘សញ្ញាសួរ◘ ◘ខ័ណ្ឌសញ្ញា◘ អោយបានត្រឹមត្រូវ ។

អ្នកជិតខាងល្អតែងតែស្រលាញ់រាប់អានគ្នាជួយគ្នាមិនថាពេលមានទុក្ខកង្វល់រឺពេលសុខសប្បាយធម្មតាទេ ពេលណាមានអាសន្ននៅក្នុងភូមិមានតែអ្នកជិតខាងទេដែលជួយយកអាសា និងជួយរំលែកទុក្ខធុរះគ្នាបានទាន់ពេល

វេលាអ្នកគិតទៅមើលបើអ្នកជិតខាងអ្នកជាសត្រូវនឹងគ្រួសារអ្នកតើគ្រួសារអ្នករស់នៅទីនោះប្រកបដោយភាពកក់ក្ដៅបានដែរឺទេអ្នកជិតខាងល្អអាចជួយធុរៈអ្នកគ្រប់ពេលវេលា ។

**<u>លំនាំនៃការបង្រៀន</u>**

១- ចំលងលំហាត់ខាងលើដាក់លើក្ដារខៀនមុនម៉ោង ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សពន្យល់ពីអ្វីដែលសិស្សត្រូវធ្វើ ប៉ុន្តែមិនមែនអោយសិស្សអានលំហាត់នោះមកវិញទេ ។

៤- ទុកពេលអោយសិស្សធ្វើលំហាត់ជាបុគ្គល ។ បើសិនសិស្សទាំងអស់ធ្វើមិនទាន់រួចទេ គ្រូត្រូវបញ្ឈប់នៅពេលណា

ដែលសិស្សចំនួនពាក់កណ្ដាល រឺជាងពាក់កណ្ដាលថ្នាក់បានធ្វើលំហាត់រួច ។

៥- ធ្វើកំនែរួមលើក្ដារខៀន ។ អោយសិស្សគូសី (ខ) ពីក្រោមកន្លែងដែលត្រូវដាក់សញ្ញាសំព័ន្ធ គូសខ័ណ្ឌសញ្ញា និង

សញ្ញាសួរដាក់ពីលើកន្លែងដែលត្រូវដាក់ ចំនែកឯដកឃ្លា មិនមានអ្វីបន្ថែមពីលើទេ ។

៦- ធ្វើការផ្ទៀងផ្ទាត់ទៅនឹងស.ស ទំព័រទី ៩៥ ( អត្ថបទនេះ មិនមែនជាអត្ថបទទំព័រទី ៩៥ ទាំងស្រុងទេ គឺយកតែផ្នែកខាងដើម និងខាងចុងតែប៉ុណ្ណោះ) ។

<u>កំនែលើក្ដារខៀន</u> :

អ្នកជិតខាងល្អ តែងតែស្រលាញ់រាប់អានគ្នា ជួយគ្នា មិនថាពេលមានទុក្ខកង្វល់ រឺពេលសុខសប្បាយធម្មតាទេ ។ ពេលណាមានអាសន្ននៅក្នុងភូមិមានតែអ្នកជិតខាងទេ ដែលជួយយកអាសា និងជួយរំលែកទុក្ខធុរៈគ្នាបានទាន់ពេលវេលា ។ អ្នកគិតទៅមើល បើអ្នកជិតខាងអ្នក ជាសត្រូវនឹងគ្រួសារអ្នក តើគ្រួសារអ្នករស់នៅទីនោះប្រកបដោយភាពកក់ក្ដៅបានដែរឺទេ ? អ្នកជិត ខាងល្អអាចជួយធុរៈអ្នកគ្រប់ពេលវេលា។

ខ- <u>លំហាត់ទី ២</u>

ចូរអានអត្ថបទស.ស ទំព័រទី ៩៥ ។

ក្នុងបញ្ជីក្រុមពាក្យទាំងពីរខាងក្រោម ចូររកក្រុមពាក្យណាដែលគ្មានក្នុងអត្ថបទនេះ ។

ចំលងក្រុមពាក្យទាំងនោះដាក់លើក្ដារឆ្នួន ។

១- យល់ចិត្តគ្នា ជួយរំលែកទុក្ខធុរៈគ្នា ជួយគ្នា គោរពសិទ្ធិគ្នា ស្រលាញ់រាប់អានគ្នា ថៃរក្សាគ្នា យោគយល់អធ្យាស្រ័យគ្នា ។

២- សេចក្ដីសុខ ភាពកក់ក្ដៅ សុខសប្បាយ ពេលមានអាសន្ន សុភមង្គល ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់ក្ដារខៀន ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សពន្យល់ពីអ្វីដែលសិស្សត្រូវធ្វើ ។

៤- ទុកពេលអោយសិស្សដើម្បីសរសេរចំលើយទាំងពីរលើក្ដារឆ្នួន ។ អោយសិស្សប្រើប្រាស់សៀវភៅអាន ។

៥- ធ្វើកំនែរួមដោយហៅសិស្សម្នាក់មកក្ដារខៀន ហើយអោយគូសជុំវិញក្រុមពាក្យដែលជ្រើសរើសយកជាចំលើយ ក្នុងបញ្ជីក្រុមពាក្យទី ១ ។ សួរសិស្សថា ហេតុអ្វីបានជាគេជ្រើសរើសយកក្រុមពាក្យនោះជាចំលើយ ។ ធ្វើដូចគ្នាចំពោះបញ្ជីក្រុមពាក្យទី ២ ។

ចំលើយ : ១- ថែរក្សាគ្នា ២- សុភមង្គល

*

* *

**ចំណុចទី ៣**

**មេរៀនទី ១**

**អំនាន : ¤ភ្នំបាណាន់¤** ស.ស ទំព័រទី ១០៣

**លំហាត់អំនានស្ងាត់**

ក- លំហាត់ទី ១

ចូររកពាក្យមកបំពេញចន្លោះក្នុងអត្ថបទខាងក្រោម ។ សរសេរចំលើយលើក្ដារឆ្នួន ។

នៅខាងលិចស្ទឹងសង្កែ ស្រុកសង្កែ ជ្រុងអាគ្នេយ៍នៃទីក្រុងបាត់ដំបង ចំងាយប្រហែលដប់គីឡូម៉ែត្រ មានភ្នំមួយឈ្មោះ................បាណន់ ។ ............ បាណន់ជាទីកន្លែង សក្ការៈយ៉ាងស័ក្តិសិទ្ធិកាលពីសម័យបុរាណ ។

កាលពីជំនាន់ដើម រៀងរាល់ឆ្នាំ នៅថ្ងៃទីមួយនៃថ្ងៃចូលឆ្នាំប្រពៃណីជាតិខ្មែរ អ្នកស្រុកធ្វើពិធីបួងសួងនៅលើ...........នោះ ។ អ្នកស្រុកបានរៀបចំគ្រឿងរណ្តាប់សំរាប់ពិធីបួងសួងមាន ស្លាធមិ បាយសី និងភ្លេងខ្មែរ ។ អ្នកស្រុកនិមន្តលោកឆាន់នៅទីនោះរួចពូន................ខ្សាច់ ។ ជូនកាល មានរបាំ ប្រដាល់ និងការចែកទាន ដល់អ្នកក្រីក្រផង ។ នៅជើង..........បាណន់ ក្នុងរូងជ្រៅមួយមានទឹកដក់ក្នុងថ្លុកថ្ម ។ អ្នកស្រុកជឿលើអព្ភូតហេតុនេះណាស់ ។ អ្នកស្រុកជឿថា បើមានទឹកដក់ពេញថ្លុកថ្ម អ្នកស្រុកនឹងធ្វើស្រូវបានបរិបូរ ។ ផ្ទុយទៅវិញ បើមានទឹកដក់តែពាក់កណ្តាលថ្លុកថ្ម អ្នកស្រុកនឹងធ្វើស្រូវពុំបាន ។ អ្នកទៅលេង........បាណន់ តែងតែសង្វាតទៅក្បង់ទឹកក្នុងថ្លុកថ្មនោះមកលុបលាងមុខ និងស្រោចក្បាលសុំសេចក្តីសុខ ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានអត្ថបទនៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់ ។ មិនមែនអោយអានលំហាត់ឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- អោយសិស្សសរសេរចំលើយនៅលើក្តារឆ្នួន ។

៦- សួរសិស្សថា តើប្អូនៗសង្កេតឃើញលំហាត់នេះមានអ្វីប្លែកគួរអោយកត់សំគាល់ដែររឺទេ ?

៧- ធ្វើកំនែរួមនៅលើក្តារខៀន ។

▫ កំនត់សំគាល់ :

- មិនអនុញ្ញាតអោយសិស្សអានអត្ថបទស.ស. ទំព័រទី ១០៣ មុន និងកំពុងធ្វើលំហាត់ឡើយ ។
- មិនត្រូវប្រាប់សិស្សថាពាក្យដែលត្រូវបំពេញជាពាក្យដូចៗគ្នាទេ ។

ចំលើយ : ភ្នំ

ខ- លំហាត់ទី ២

ចូរផ្ទៀងផ្ទាត់សំនើទាំងបួនខាងក្រោមទៅនឹងអត្ថបទទំព័រទី ១០៣ ថា ត្រូវ រឺ ខុស ។

សរសេរ "ត្រូវ " លើក្តារឆ្នួន ចំពោះឈ្មោះដែលមានន័យសមស្របតាមខ្លឹមសារអត្ថបទតាមគំរូខាងក្រោម :

| | |
|---|---|
| ១ | |
| ២ | |

| | |
|---|---|
| ២ | |
| ៣ | |
| ៤ | |

| | | |
|---|---|---|
| ១ | | នៅលើភ្នំបាណន់មានរូងជ្រៅមួយ ។ |
| ២ | | ភ្នំបាណន់ ជាទីកន្លែងសក្ការៈយ៉ាងស័ក្តិសិទ្ធិ ។ |
| ៣ | | អ្នកស្រុកនិមន្តលោកទៅឆាន់ក្បែរភ្នំនោះ ។ |
| ៤ | | នៅខាងលិចស្ទឹងសង្កែ ចំងាយប្រហែលដប់គីឡូម៉ែត ពីជ្រុងអាគ្នេយ៍នៃទីក្រុងបាត់ដំបង មានភ្នំមួយ ឈ្មោះ ភ្នំបាណន់ ។ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានលំហាត់នៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ។ មិនមែនអោយអានលំហាត់ឡើងវិញឡើយ ។

៤- ទុកពេលអោយសិស្សធ្វើលំហាត់ ។

៥- ធ្វើកំនែរួមនៅលើក្តារខៀន ។ អោយសិស្សឡើងសរសេរ "ត្រូវ" រឺ "ខុស" នៅមុខឃ្លាណា ដែលគេយល់ថា "ត្រូវ" រឺ "ខុស" រួចអោយសិស្សបញ្ជាក់ពីហេតុផលនៃការជ្រើសរើសនោះ ។

ចំលើយ :

| | |
|---|---|
| ១ | ខុស |
| ២ | ត្រូវ |
| ៣ | ខុស |
| ៤ | ត្រូវ |

*

*  *

**ជំពូកទី ៣**

**មេរៀនទី ២**

**អំនាន : ◘សិប្បកម្មនៅប្រទេសកម្ពុជា◘** ស.ស ទំព័រទី ១១១

**លំហាត់អំនានស្ទាត់**

ក- លំហាត់ទី ១

ចូរអានអត្ថបទស.ស ទំព័រទី ១១១ ដោយស្ងៀមស្ងាត់ ។

នៅក្នុងជួរ " ក " ខាងក្រោមអ្នកឃើញឈ្មោះខេត្តផ្សេងៗនៃប្រទេសកម្ពុជា ។

នៅក្នុងជួរ " ខ " អ្នកឃើញផលិតផលនានានៃខេត្តទាំងនោះ ។

ចូរសរសេរខេត្តទាំងបួន និងផលិតផលនានារបស់ខេត្តដែលមានក្នុងអត្ថបទដាក់ក្នុងសៀវភៅ របស់អ្នក ។

ឧទាហរណ៍ : ខេត្តកណ្តាល : ហូល កន្ទេល ក្រមា

| ក | ខ |
|---|---|
| ១- តាកែវ<br>២- សៀមរាប<br>៣- កំពង់ធំ<br>៤- កំពង់ឆ្នាំង | ក្អម ចំលាក់ឈើ កញ្ជើ ផាមួង<br>ការដាប់ស្បែក អង្រុត ឆ្នាំង<br>ហូល ចំលាក់ប្រាក់ ចង្អេរ កន្ទេល ស្បៃត្រ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានលំហាត់នៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣-អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់។ មិនមែនអោយអានលំហាត់ឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- ធ្វើកំនែរួមដោយអោយសិស្ស ២ រឺ ៣នាក់ ឆ្លើយផ្ទាល់មាត់ឡូវផលិតផលរបស់ខេត្ត ទីមួយ ។ គ្រូធ្វើសំយោគ រួចសរសេរចំលើយទីមួយនៅលើក្តារខៀន ។ ធ្វើដូចគ្នាចំពោះខេត្តផ្សេងៗទៀត ។

ចំលើយ :

១- តាកែវ : ហូល ផាមួង ស្បៃត្រ

២- សៀមរាប : ចំលាក់ឈើ ការដាប់ស្បែក ចំលាក់ប្រាក់ ។

៣- កំពង់ធំ : គ្មាន

៤-កំពង់ឆ្នាំង : ក្អម កញ្ជើ អង្រុត ឆ្នាំង ចង្អេរ កន្ទេល ។

ខ- លំហាត់ទី ២

ចូរផ្ទៀងផ្ទាត់សំនើទាំង ៥ ខាងក្រោមទៅនឹងអត្ថបទទំព័រទី ១១១ ថាត្រូវ រឺខុស ។

ចូរសរសេរចំលើយនៅលើក្តារឆ្នួន ដោយដាក់ថាត្រូវរឺខុស នៅក្បែរលេខដែលតំនាងអោយល្បះនីមួយៗ ។

| | | |
|---|---|---|
| ១ | | ប្រទេសកម្ពុជាមានសិប្បកម្មតែមួយប្រភេទ ។ |
| ២ | | សព្វថ្ងៃ ប្រទេសកម្ពុជាកំពុងអភិវឌ្ឍសិប្បកម្មទាំងនេះអោយរីកចំរើន ។ |
| ៣ | | សិប្បកម្មខ្មែរមានជីវិតដោយសារប្រជាជននិយមចូលចិត្តស្នាដៃទាំងនេះ ។ |
| ៤ | | ដើម្បីអោយសិប្បកម្មខ្មែរកាន់តែរីកចំរើន យើងត្រូវនិយមប្រើរបស់មកពីបរទេស ។ |
| ៥ | | សិប្បកម្មខ្មែរ  មានតាំងពីយូរយារណាស់មកហើយ ។ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានអត្ថបទនៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣-អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់ ។ មិនមែនអោយអានលំហាត់ឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- ធ្វើកំនែរួមដោយហៅសិស្សម្នាក់អោយឆ្លើយល្បះទី ១ ថាត្រូវ រឺ ខុស រួចសួរបញ្ជាក់ ពីហេតុផលនៃការជ្រើសរើសនេះ ។ គ្រូសរសេរ ◘ខុស◘ នៅក្នុងប្រអប់ទី ១ ដែលមានលើ ក្តារខៀនស្រាប់ ។ បន្ទាប់មកគ្រូហៅសិស្សទី២ អោយឆ្លើយដោយធ្វើរបៀបនេះរហូតដល់ ចប់ ។

ចំលើយ :
១ - ខុស
២- ត្រូវ
៣- ត្រូវ
៤- ខុស
៥- ត្រូវ

*

*   *

**ជំពូកទី ៣**

**មេរៀនទី ៣**

## អំនាន : ◘សាមគ្គីភាពនៅក្នុងសហគមន៍◘ ស.ស ទំព័រទី ១១៩

**លំហាត់អំនានស្ងាត់**

**ក- លំហាត់ទី ១**

អត្ថបទនេះមានពាក្យ ៥ ដែលសរសេរលើស ។ ចូររកពាក្យទាំងនោះ ។ ចំលងពាក្យនោះដាក់លើក្ដារឆ្នួនដោយបញ្ជាក់ពីលេខបន្ទាត់របស់វា ដូចឧទាហរណ៍ខាងក្រោម :

១ - ជាង

១- សហគមន៍ណាមានសាមគ្គីភាពជាងល្អ សហគមន៍នោះមានសេចក្ដីសុខ ។

២- ក្នុងច្រើនសហគមន៍នីមួយៗ តែងតែមានជនជាតិផ្សេងៗរស់នៅ

៣- និងផ្សេងៗប្រកបរបររកស៊ីចិញ្ចឹមជីវិតប្លែកៗគ្នា ។

៤- ទំនាក់ទំនងគិតគ្នាក្នុងមុខរបរចិញ្ចឹមជីវិត អាចអោយពួកគេចេញយោគយល់គ្នា

៥- និងបំពេញតំរូវការគ្នាទៅវិញទៅមក ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្ដារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានអត្ថបទនៅលើក្ដារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់ ។ មិនមែនអោយអានលំហាត់ឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- ធ្វើកំនែរួមលើក្ដារខៀន ។ ហៅសិស្សម្នាក់ឡើងមកគូសខ្វែងចោល ចំពោះពាក្យដែលលើសទាំងនោះ ។ ចំពោះថ្នាក់ដែលសិស្សមិនអាចរកឃើញចំលើយតែម្ដងបាន គ្រូធ្វើកំនែម្ដងមួយឃ្លាៗ រួចអោយសិស្សមកគូសខ្វែងចោលពាក្យលើសនោះម្ដងមួយៗ តាមបន្ទាត់នីមួយៗ ។

ចំលើយ :

១- ជាង

២- ច្រើន

៣- ផ្សេងៗ

៤- គិត - ចេញ

៥- ០

**ខ- លំហាត់ទី ២**

អត្ថបទខាងក្រោមនេះបាត់ឃ្លា ៣ ៖

១- សហគមន៍នោះ នឹងធ្លាក់ចុះដុនដាប

២- ក្នុងសហគមន៍ គួរតែរួបរួមគ្នា

៣- ពួកគេមានទឹកចិត្តស្រលាញ់រាប់អានគ្នា

ក- រកកន្លែងរបស់ឃ្លាទាំងនោះនៅក្នុងអត្ថបទ ៖

ខ- សរសេរចំលើយជាលេខរបស់ឃ្លានោះ ព្រមទាំងពាក្យដែលនៅពីមុខ និង ពីក្រោយលើក្ដារឆ្នួនដូច ឧទាហរណ៍ខាងក្រោម ៖

ទាំងអស់ ២ និង ចេះ . . . . .

ពួកគេតែងតែជួយគ្នាទៅវិញទៅមក ក្នុងមុខរបររកស៊ី ក៏ដូចជាទំនាក់ទំនងធម្មតា ក្នុងការរស់នៅជារៀង រាល់ថ្ងៃដែរ ។ ម្យ៉ាងទៀត យ៉ាងស្មោះស្ម័គ្រគ្មានគំនិតគុំគួន គ្មានការច្រណែនឈ្នានីសឡើយ ។ បើមនុស្សក្នុង សហគមន៍ខ្វះសាមគ្គីភាព ដោយសារវិបត្តិផ្សេងៗ ដូចជា ភាពក្រីក្រ អសន្តិសុខ និងអនាធិបតេយ្យជាដើម ។

ប្រជាជនទាំងអស់ និងចេះសហការគ្នាទើបសហគមន៍មានសេចក្ដីសុខ និងរីកចំរើន ។

**<u>លំនាំនៃការបង្រៀន</u>**

១- ចំលងលំហាត់ដាក់លើក្ដារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានអត្ថបទនៅលើក្ដារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់ ។ មិនមែនអោយអានលំហាត់ឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- អោយសិស្សបង្ហាញចំលើយដែលសរសេរលើក្ដារឆ្នួន ។

៦- ធ្វើកំនែរួមលើក្ដារខៀន ។ ហៅសិស្សម្នាក់អោយមកសរសេរចំលើយដូចឧទាហរណ៍ខាងលើ នៅលើក្ដារខៀន រួចអោយសរសេរលេខដែលត្រូវដាក់នោះក្នុងអត្ថបទលំហាត់ដែលមានស្រាប់ ។ បន្ទាប់មកអោយសិស្សអាន ល្បះពេញលេញ ដែលគេរកឃើញនេះ ។ ធ្វើដូចគ្នាចំពោះឃ្លាមួយទៀត ។

<u>ចំលើយ</u> :

| | | |
|---|---|---|
| ទាំងអស់ | ២ | ចេះ |
| ម្យ៉ាងទៀត | ៣ | យ៉ាង |
| សាមគ្គីភាព | ១ | ដោយ |

*

*   *

## ជំពូកទី ៣

## មេរៀនទី ៤

## អំណាន : ▫ កិត្តិស័ព្ទលោកតាក្រមង៉ុយ▫ ស.ស. ទំព័រទី ១២៧

**លំហាត់អំណានស្ទាត់**

ក- លំហាត់ទី ១

ចូរអានអត្ថបទខាងក្រោម ។ ចំលងអត្ថបទនេះឡើងវិញដាក់ក្នុងសៀវភៅអ្នក ដោយដាក់ ▫ខ័ណ្ឌសញ្ញា▫ ( ។ ) និង ▫ដកឃ្លា▫ អោយបានត្រឹមត្រូវតាមទីតាំង ។

លោកតាក្រមង៉ុយកើតនៅឆ្នាំ១៨៦៥គាត់បានបួសរៀននៅវត្តបឹងអង្គចកឃុំបែកចានស្រុកអង្គស្នួលខេត្តកណ្តាលលោកជាអ្នកចំរៀងសាយដៀវនិងជាកវីមួយរូបដែលមានកេរ្តិ៍ឈ្មោះល្បីលោកបានបន្សល់ទុកស្នាដៃល្អៗដូចជាបណ្តាំក្រមង៉ុយច្បាប់កេរកាលថ្មីជាដើម

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានអត្ថបទនៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់ ។ មិនមែនអោយអានលំហាត់ឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- ធ្វើកំនែរួមលើក្តារខៀនដោយ ▫

- អោយសិស្សឡើងគូសសញ្ញា ( | ) ត្រង់កន្លែងណាដែលត្រូវដកឃ្លា ។
- អោយសិស្សឡើងគូស (5) ពីក្រោមកន្លែងណាដែលត្រូវដាក់សញ្ញាខ័ណ្ឌ រួចគូសសញ្ញាខ័ណ្ឌ ( ។ ) នោះនៅពីលើ ។

ឧទាហរណ៍ :

លោកតាក្រមង៉ុយកើតនៅឆ្នាំ១៨៦៥ ។ គាត់បានបួសរៀន នៅវត្តបឹងអង្គចក ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ។ លោកជាអ្នកចំរៀងសាយដៀវ និងជាកវីមួយរូបដែលមានកេរ្តិ៍ឈ្មោះល្បី ។ លោកបានបន្សល់ទុកស្នាដៃល្អៗដូចជា បណ្តាំក្រមង៉ុយ ច្បាប់កេរកាលថ្មីជាដើម ។

៦- អោយសិស្សផ្ទៀងផ្ទាត់កំនែនេះទៅនឹងអត្ថបទក្នុងសៀវភៅរៀនអានទំព័រ ១២៧ ។

៧- អោយសិស្ស ២ នាក់ អានអត្ថបទ (អំនានលឺ) ។

ខ- លំហាត់ទី ២

ចូរអានអត្ថបទខាងក្រោម រួចរកអោយឃើញពាក្យខុសចំនួន ៤ពាក្យ ។ ស្រង់ពាក្យទាំងនោះ ដាក់ក្នុងសៀវភៅ រួចធ្វើកំនែពាក្យទាំងនោះអោយបានត្រឹមត្រូវ ។

ដោយសារលោកមានស្នាដៃល្អ និងថ្វីមាត់ពិសេស ប្រកបដោយគំនិតអប់រំ ទើបប្រជាជនទូទៅនិយមចូលចិត្ត ទឹកដមសំដីរបស់លោកយ៉ាងជ្រាលជ្រៅ នៅក្នុងផ្លូវការណ៍ លោកបានទទួលងារ "ក្រមការ" ហើយគេហៅលោកថា " លោកតាក្រមង៉ុយ " ។

យើងជាកូនខ្មែរជំនាន់ក្រោយ ត្រូវតែខិតខំសិក្សា ស្វែងយល់ ចងចាំ ស្នាដៃនិពន្ធ របស់បុព្វបុរសយើង ។ យើងត្រូវថែរក្សាស្នាដៃទាំងនោះ អោយបានគង់វង់ ដើម្បីទុកជាមរកតបន្តទៅអ្នកជំនាន់ក្រោយៗទៀត ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានលំហាត់នៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់។ មិនមែនអោយអានលំហាត់ឡើងវិញទេ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- អោយសិស្សដូរកិច្ចការគ្នាកែ ។

៦- ធ្វើកំនែរួមលើក្តារខៀន ។

៧- អោយសិស្សម្នាក់ វឺ ២ នាក់អានអត្ថបទដែលកែរួចឡើងវិញ ។

ចំលើយ : ចូលចិត្ត ផ្លូវការ គង់វង្ស មរតក ។

*

* *

## ជំពូកទី ៤

## មេរៀនទី ១

**អំណាន : ◘ជីវភាពអ្នកនេសាទ◘** ស.ស. ទំព័រទី ១៣៥

**លំហាត់អំណានស្ទាត់**

ក- លំហាត់ទី ១

ចូរជ្រើសរើសពាក្យក្រៅក្រុមមួយ នៅក្នុងបញ្ជីក្រុមពាក្យនីមួយៗខាងក្រោម ។ ចំលងពាក្យនោះដាក់លើក្តារឆ្នួន ។

១- មង អួន សំនាញ់ ទ្រូ អន្ទាក់ លប សន្ទូច ។

២- ប្រហុក ផ្អក ស្ករ ត្រីងៀត ត្រីឆ្អើរ ត្រីស្ងោរ ទឹកត្រី ។

៣- ប្រឡាយទឹក បឹង ស្ពាន ទន្លេ អូរ ត្រពាំង ស្ទឹង ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានលំហាត់នៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់ ។ មិនមែនអោយអានលំហាត់ឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- អោយសិស្សលើកចំលើយលើក្តារឆ្នួនបង្ហាញគ្រូ ។

៦- អោយសិស្សម្នាក់ឡើងមកគូសជុំវិញ រឺគូសពីក្រោមពាក្យក្រៅក្រុមក្នុងបញ្ជីក្រុមពាក្យទី ១ នៅលើក្តារខៀន ។
សួរសមូហភាពសិស្សថាតើត្រឹមត្រូវរឺទេ ? អោយសិស្សនោះធ្វើអំនះអំនាងលើ ចំលើយរបស់ខ្លួន ។
ចំពោះចំលើយណាដែលសមូហភាពថ្នាក់ទាំងមូលយល់ថាត្រឹមត្រូវ គ្រូគួរទទួលយកចំលើយនោះទុកជាបានការ ។

ធ្វើដូចគ្នាចំពោះពាក្យក្រៅក្រុមដែលនៅក្នុងបញ្ជីពាក្យ ទី ២ និង ទី ៣ ។

ចំលើយ : ១- អន្ទាក់ (ពីព្រោះមិនមែនជារបស់សំរាប់ដាក់ត្រីទេ តែសំរាប់ដាក់សត្វ)

២- ស្ករ (ពីព្រោះមិនមែនជាម្ហូបធ្វើពីត្រី)

៣- ស្ពាន (ពីព្រោះមិនមែនបញ្ជាក់ពីកន្លែងដែលមានទឹក) ។

ខ- លំហាត់ទី ២

ចូរអានពាក្យក្នុងតារាងខាងក្រោម រួចគូសព្រួញភ្ជាប់ពាក្យពីឆ្វេងទៅស្តាំ ពីលើចុះក្រោម រឺ ពីក្រោមឡើងលើ ដើម្បីផ្គុំអោយបានជាល្បះពីរដែលមាននៅក្នុងអត្ថបទ ។ ហាមគូសកាត់ខ្វែងតាមជ្រុង រឺរំលងប្រអប់ ។ បន្ទាប់មក ចូរចំលងល្បះទាំងនោះដាក់ក្នុងសៀវភៅ រួចផ្ទៀងផ្ទាត់ទៅនឹងអត្ថបទ ទំព័រទី ១៣៥ ។

| | | | | | |
|---|---|---|---|---|---|
| គ្រួ | នេសាទ | មមាញឹក | ណាស់ | ក្នុង | ផ្ទះ |
| សារ | អ្នក | ស្រែ | ក្នុង | មុខ | គោក |
| ពេល | ទឹក | បង់ | សំនាញ់ | របរ | ខ្លួន |
| ភ្លៀង | ស្រក | គេ | រឺ | អូស | អួន |

លំនាំនៃការបង្រៀន

១- ចំលងលំហាត់ដាក់លើក្តារខៀន និងចំលងតារាងពាក្យលើក្រដាសសំរាប់ចែកសិស្សតាមក្រុម ។

២- អោយសិស្សអានលំហាត់នៅលើក្តារខៀនដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ។

៤- ចែកតារាងពាក្យអោយសិស្សធ្វើលំហាត់តាមក្រុម ។ ទុកពេលអោយសិស្សធ្វើលំហាត់ ។ គ្រូដើរពិនិត្យកិច្ចការ ។

៥- អោយតំនាងក្រុមណាមួយឡើងគូសព្រួញភ្ជាប់ពាក្យក្នុងតារាង រួចអោយអានល្បះដែលក្រុមខ្លួនបានគូសភ្ជាប់រួច ។ សិស្សឯទៀតផ្ទៀងផ្ទាត់ចំលើយទៅនឹងអត្ថបទ ។

៦- សរសេរចំលើយនៅលើក្តារខៀន ។

៧- អោយសិស្សកែកំហុស និងចំលងដាក់ក្នុងសៀវភៅ ។

ចំលើយ : ល្បះទី ១ ៖ ពេលទឹកស្រកគេបង់សំនាញ់ រឺអូសអួន ។

ល្បះទី ២ ៖ គ្រួសារអ្នកនេសាទមមាញឹកណាស់ក្នុងមុខរបរខ្លួន ។

*

*                        *

# ជំពូកទី ៤

## មេរៀនទី ២

### មេសូត្រ : ■គ្រូវឧស្សាហ៍ដាំ និងថែជំនាំ■  ស.ស ទំព័រទី ១៤៣

**លំហាត់អំនានស្ងាត់**

ក- លំហាត់ទី ១

ក្នុងកំនាព្យខាងក្រោមនេះមានកំហុស ៤ ។ ចូររកពាក្យនោះនិងសរសេរកែតំរូវ ។ សរសេរចំលើយលើក្តារឆ្នួន ។

**គ្រូវឧស្សាហ៍ដាំនិងថែជំនាំ** (បទព្រហ្មគីតិ)

| | |
|---|---|
| រដូវធ្វើស្រែចំការ | អោយឧស្សាហ៍គ្រៀងគ្រាប់ដាំ |
| ស្លឹកគ្រៃ ថ្មី ត្រប់ ត្រុំ | ត្រាវត្រសក់សព្វបន្លែ ។ |
| កុំខ្ជិលកុំច្រអុស | ទៅងង្សសរកសុំគេ |
| គេមិនអោយឯងទេ | តែគឺមោះព្រោះខ្ជិលដាំ ។ |
| ទៅធ្វើស្រែចំការ | អោយឧស្សាហ៍មើលថែទាំ |
| កុំខ្ជិលកុំប្រចាំ | ចប់ចៀកជីកស្មៅវល្លិផង ។ |
| កុំអោយបងកំលាំង | ទោះខែប្រាំងត្រូវតែដង |
| ទឹកទៅស្រោចស្រពផង | អោយលូតលាស់មាន់ផ្លែផ្កា ។ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានលំហាត់នៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់ ។ មិនមែនអោយអានលំហាត់ឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- អោយសិស្សបង្ហាញចំលើយលើក្តារឆ្នួន ។

៦- ធ្វើកំនែរួមនៅលើក្តារខៀន ។ អោយសិស្សម្នាក់ រឺ ពីរនាក់ឡើងមកគូសពីក្រោមពាក្យខុសទាំងនោះ រួចអោយ

កែពាក្យទាំងនោះអោយត្រឹមត្រូវឡើងវិញ ។

ចំលើយ : ច្រអុស Π ច្រអូស

ចប់ Π ចប

បង Π បង់

មាន់ Π មាន

ខ- លំហាត់ទី ២

អត្ថបទពាក្យកាព្យខាងក្រោម មានឃ្លាពីរដែលខុសពីន័យអត្ថបទមេសូត្រទំព័រទី ១៤៣ ។

| | |
|---|---|
| ១- រដូវធ្វើស្រែចំការ | ២- អោយឧស្សាហ៍ត្រួងគ្រាប់ដាំ |
| ៣- ស្លឹកគ្រៃផ្ទីត្រប់ត្រុំ | ៤- ត្រាវត្រសក់សព្វបន្លែ ។ |
| ៥- កុំខ្ជិលកុំច្រអូស | ៦- រត់បង្ហួសទៅទន្លេ |
| ៧- គេមិនអោយឯងទេ | ៨- តែគឺមោះព្រោះខ្ជិលដាំ ។ |
| ៩- ចូលលេងផ្ទះម៉ាក់ប៉ា | ១០- អោយឧស្សហ៍មើលថែទាំ |
| ១១- កុំខ្ជិលកុំប្រចាំ | ១២- ចបច្បកជីកស្មៅវល្លិផង ។ |

ក- រកឃ្លាដែលខុស ហើយសរសេរលេខនៃឃ្លាទាំងពីរនោះដាក់ក្ដារឆ្នួន ។

ខ- ខាងក្រោមនេះ មានឃ្លាបួន ។ ជ្រើសរើសឃ្លាពីរ ដែលត្រូវនឹងអត្ថបទមេសូត្រ ។ សរសេរចំលើយលើក្ដារឆ្នួន ។

- ត្រូវឧស្សាហ៍ច្រូងនិងរាំ
- ទៅងងឿសរកសុំគេ
- អោយល្បេតលាស់ស្លឹកនិងផ្កា
- ទៅធ្វើស្រែចំការ

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្ដារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានលំហាត់នៅលើក្ដារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់ ។ មិនមែនអោយអានលំហាត់ឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- ធ្វើកំនែរួមនៅក្ដារខៀន ។ អោយសិស្សផ្ទៀងផ្ទាត់នៅនឹងអត្ថបទទំព័រទី ១៤៣ ហើយអោយសិស្ស ២ រឺ ៣នាក់ឆ្លើយផ្ទាល់មាត់ ។ គូសជុំវិញលេខឃ្លាដែលខុស និងលុបឃ្លាទាំងនោះចោល ។

៦- អោយសិស្សឆ្លើយសំនួរ " ខ" ដោយសរសេរឃ្លាត្រឹមត្រូវដែលគេបានជ្រើសរើសនៅលើក្ដារឆ្នួន ។

៧- ធ្វើកំនែសំនួរ "ខ " នៅក្ដារខៀន។ អោយសិស្ស ២ រឺ ៣នាក់ឆ្លើយ ។ គ្រូសរសេរឃ្លាត្រូវបំពេញកន្លែងដែលលុប

នៅលើក្ដារខៀន រួចហើយអោយសិស្សអានអត្ថបទលំហាត់ដែលបានកែរួចនោះ អោយបាន ២ រឺ ៣ ចប់ ។

<u>ចំលើយ</u> : ក/ ៦ - ៩

ខ/ - ទៅរងរ្សវរកសុំគេ

- ទៅធ្វើស្រែចំការ

* * *

**<u>ជំពូកទី ៤</u>**

**<u>មេរៀនទី ៣</u>**

**<u>អំនាន</u> : ◘មិត្តសំលាញ់ពិសេស◘** ស.ស. ទំព័រទី ១៥១

**<u>លំហាត់អំនានស្ងាត់</u>**

ក- <u>លំហាត់ទី ១</u>

ចូរជ្រើសរើសពាក្យក្នុងសំនើនៃល្បះនីមួយៗ ដើម្បីអោយល្បះនោះមានន័យត្រឹមត្រូវ ។ ចំលងល្បះដែលត្រូវដាក់ក្នុងសៀវភៅ រឺក្រដាសព្រាង ។

ដែរ

↗ ↘

- អាចំប៉ាក៏មានរាងសង្ហា តែខ្លួនវាខ្លីជាងខ្លួនអាត្នោត ។

↘ ↗

ដើរ

ទៅ

↗ ↘

- ខ្ញុំយកស្មៅមួយកង អោយអាចំប៉ាស៊ី ។

↘ ↗

នៅ

ក្អមៗ

↗ ↘

- ខ្ញុំបបោសខ្លួនអាចំប៉ា រួចខ្ញុំទៅមើលអាត្នោត ។

↘ ↗

ថ្មម៉ៗ

មិត្ត

↗ ↘

- អាត្នោតនិងអាចំប៉ា សំលាញ់ពិសេសរបស់ខ្ញុំ ។

↘ ↗

ចិត្ត

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្ដារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានអត្ថបទនៅលើក្ដារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់។ មិនមែនអោយអានលំហាត់ឡើងវិញទេ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- ធ្វើកំនែរួមលើក្ដារខៀន ។ ហៅសិស្សម្នាក់ឡើងមកគូសខ្វែងចោលពាក្យដែលមិនត្រូវនឹងន័យនៃឈ្នះ ។ អោយ

សិស្ស ១ នាក់ រឺ ២ នាក់ អានឃ្លាត្រូវទី ១ នេះ ។ ធ្វើដូចគ្នាចំពោះឃ្លា ទី ២ ទី ៣ ទី ៤ ។

<u>ចំលើយ</u> : ដែរ - ទៅ

ថ្មម៉ៗ - មិត្ត

ខ- <u>លំហាត់ទី ២</u>

អត្ថបទខាងក្រោមនេះមានឃ្លាមួយដែលលើស ។ ចូររកឃ្លានោះ រួចចំលងដាក់សៀវភៅអ្នក ។

<u>មិត្តសំលាញ់ពិសេស</u>

គ្រួសារខ្ញុំ ចញ្ចឹមគោមួយនឹម ។ មួយឈ្មោះអាត្នោត ព្រោះវាមានសំបុរក្រហមក្រមៅ ។ ឯមួយទៀតឈ្មោះអាចំប៉ា ព្រោះវាមានសំបុរស ។

អាត្នោតជាគោកូនក្រោល ។ វាកំព្រាមេ តាំងពីវាកើតបាន បីខែម្ល៉េះ ។ អាត្នោតមានមាឌធំ មើលទៅរាងសង្ហា ។ ក្បាលវាសំប៉ែត ។ ស្នែងវាខ្លី រាងដូចទំពាំងដែលទើបល្បៀតផុតពីដី ។ អាត្នោតមានសំបុរក្រហមក្រមៅរោមវារលោង ។ អាទែកឈរស៊ីស្មៅនៅមាត់បឹងធ្វើព្រងើយ ។ អាចំប៉ាក៏មានរាងសង្ហាដែរ តែខ្លួនវាខ្លីជាងអាត្នោតបន្តិច ។

ថ្ងៃមួយ ពេលត្រឡប់មកពីសាលាវិញ ខ្ញុំឃើញអាត្នោតឈរសញ្ជប់សញ្ជឹងនៅក្នុងក្រោល និងឃើញអាចំប៉ា

| |
|---|
| នៅក្រោមដើមអំពិលបារាំង ។ វាស្រែកម៉ៗ ហើយសំលឹងទៅអាត្មោត ។ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២-អោយសិស្សអានអត្ថបទនៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។ មិនអនុញ្ញាតអោយអានសៀវភៅពុម្ពទេ ។

៣-អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ដោយពាក្យសំដីរបស់គេផ្ទាល់ ។ មិនមែនអោយអានលំហាត់ឡើងវិញទេ ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល ។

៥- ធ្វើកំនែរួមដោយអោយសិស្ស ២ រឺ ៣ នាក់ អានល្បះចំលើយរបស់ខ្លួន ។ អោយសិស្សផ្ទៀងផ្ទាត់ចំលើយ ទៅនឹងអត្ថបទ ។ អោយសិស្សម្នាក់ទៀតមកគូសល្បះដែលលើសនោះ នៅក្តារខៀនចោល ។

ចំលើយ : អាទែកឈរស៊ីស្មៅនៅមាត់បឹងធ្វើព្រងើយ ។

**ជំពូកទី ៤**

**មេរៀនទី ៤**

**អំនាន : ❑គីសមុទ្រ និង កន្ត្រៃបង្កុក❑** ស.ស. ទំព័រទី ១៥៩

**លំហាត់អំនានស្ងាត់**

| |
|---|
| ក- លំហាត់ទី ១ |
| ចូរភ្ជាប់ឃ្លានៃផ្នែក"ក" ទៅនឹងពាក្យមួយនៃផ្នែក"ខ" ដើម្បីអោយបានជាល្បះដែលមាននៅក្នុងអត្ថបទ ទំព័រទី ១៥៩ ។ សរសេរចំលើយលើក្តារឆ្នួនរបស់អ្នកតាមគំរូឧទាហរណ៍ ខាងក្រោម ▫ ១ ∏ គ |
| **ក** **ខ** |
| ១- មានមនុស្សម្នាក់រស់នៅជិត |
| ក- ថ្កុក ។ |
| ២- គាត់ដាក់គីក្នុង |
| ៣- គីលោតពីកញ្ច្រោងទៅក្នុង ខ- កញ្ច្រោង ។ |
| ៤- គីមានរូបរាងដូចកំពឹសដែរ តែវារស់នៅក្នុង គ- សមុទ្រ ។ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានលំហាត់នៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣-អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់ ។ មិនមែនអោយអានលំហាត់ឡើងវិញទេ។

៤- អោយសិស្សអានលំហាត់ម្តងទៀត ដោយស្ងាត់ស្ងៀម និងដោយប្រុងប្រយ័ត្ន ព្រោះបន្តិចទៀត នឹងត្រូវបិទលំហាត់នេះ ដើម្បីអោយសិស្សអានអត្ថបទវិញម្តង ។

៥- បិទវាំងននលាក់លំហាត់ រួចអោយសិស្សបើកសៀវភៅអានអត្ថបទទំព័រទី ១៥៩ ដោយប្រុងប្រយ័ត្ន ។ បញ្ជាក់ប្រាប់សិស្សថា ត្រូវអានស្ងាត់ដោយយកចិត្តទុកដាក់ ព្រោះបន្តិចទៀតត្រូវធ្វើលំហាត់អំបាញ់មិញ ។

៦- ពេលសិស្សអានចប់ ត្រូវអោយសិស្សបិទសៀវភៅ ។

៧- បើកវាំងនន អោយសិស្សធ្វើលំហាត់ ដោយទុកពេលអោយសិស្សត្រិះរិះពិចារណាជាបុគ្គល ។

៨- អោយសិស្សបង្ហាញចំលើយលើក្តារឆ្នួន ។

៩- អោយសិស្សម្នាក់ឡើងមកគូសភ្ជាប់ឃ្លានៅក្តារខៀន ។ គ្រូសរសេរចំលើយលើក្តារខៀន សិស្សឯទៀតផ្ទៀងផ្ទាត់ចំលើយទៅនឹងអត្ថបទ ។

<u>ចំលើយ</u> :

| | | |
|---|---|---|
| ១ | ∏ | គ |
| ២ | ∏ | ខ |
| ៣ | ∏ | ក |
| ៤ | ∏ | គ |

ខ- <u>លំហាត់ទី ២</u>

ចូរអានល្បះខាងក្រោម ។

តើពាក្យដែលគូសបន្ទាត់ពីក្រោមនេះ ជំនួសពាក្យអ្វីនៅក្នុងអត្ថបទ ? ចូរឆ្លើយដោយសរសេរលើក្តារឆ្នួន រឺក្នុងសៀវភៅរបស់អ្នក ។

១- <u>វា</u>លោតផ្លោតចេញពីកញ្ច្រែង រួចមុជទៅក្នុងទឹកថ្លុកនោះ ។

២- ◘ តើពីមុនឯងនៅឯណា បានជា <u>ខ្ញុំ</u> មិនស្គាល់ឯងអ៊ីចឹង ? ◘

៣- ◘ ទេ ! ខ្ញុំថាបើ<u>វា</u> ធំណាស់ក៏ប៉ុនថ្លុកនេះឯង ។ ◘

៤- <u>ខ្លះ</u> ធំប៉ុនកោះ ប៉ុនភ្នំក៏មានដែរ ។

<u>ឧទាហរណ៍</u> : វា ជំនួស គី

## <u>លំនាំនៃការបង្រៀន</u>

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានលំហាត់នៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣-                                              អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់។ មិនមែនអោយអានលំហាត់ឡើងវិញទេ។

៤- ទុកពេលអោយសិស្សធ្វើលំហាត់ ដោយអនុញ្ញាតអោយសិស្សបើកសៀវភៅអាន ។

៥- អោយសិស្សបង្ហាញចំលើយ រួចធ្វើកំនែរួមផ្ទាល់មាត់ ។

៦- គ្រូ រឺសិស្សសរសេរចំលើយនៅលើក្ដារខៀន ។

<u>ចំលើយ</u> :        ១- ◘ វា ◘  ជំនួស គី

២- ◘ ខ្ញុំ ◘  ជំនួស កង្កែប

៣- ◘ វា ◘  ជំនួស សមុទ្រ

៤- ◘ ខ្លះ ◘  ជំនួស ត្រី

*

*                    *

## <u>ជំពូកទី ៤</u>

## <u>មេរៀនទី ៥</u>

**<u>អំនាន</u> : ◘ផ្លូវគមនាគមន៍◘**        ស.ស ទំព័រទី ១៦៦

**<u>លំហាត់អំនានស្ទាត់</u>**

ក- <u>លំហាត់ទី ១</u>

ចូរអានអត្ថបទខាងក្រោមនេះ រួចរកកន្សោមពាក្យមកបំពេញត្រង់សញ្ញា (..........) ដោយផ្អែកទៅតាមន័យរបស់អត្ថបទ ។ ចំលងពាក្យទាំងនោះដាក់លើក្ដារឆ្នួនរបស់អ្នក ។

(.........) ការធ្វើដំនើរពីកន្លែងមួយទៅកាន់កន្លែងមួយ នៅឡើទាំងផ្ទៃប្រទេសងាយស្រួល និង឵ ឆាប់រហ័សជាងជំនាន់ដើម ។

(..........) គេធ្វើដំនើរ និងដឹកជញ្ជូនផលិតផលផ្សេងៗ ទៅកាន់ទីកន្លែងនានា ដោយប្រើរទេះគោ រទេះសេះ ទូក កប៉ាល់ រឺ សំពៅ ។ ការធ្វើដំនើរនៅសម័យនោះ ពុំឆាប់រហ័សទាន់ចិត្ត និងជួបការលំបាកច្រើន ។ ឥលូវនេះ គេមាន (.........) ធ្វើដំនើរច្រើនយ៉ាង ហើយទំនើបៗ ដូចជា យន្តហោះ កប៉ាល់ល្បឿន កាណូត ទូកម៉ាស៊ីន រថយន្ត រថភ្លើង

ម៉ូតូ... គេអាចចំនាយពេលតិច ហើយងាយស្រួលជាងមុនច្រើនណាស់ ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានអត្ថបទនៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់។ មិនមែនអោយអានលំហាត់ឡើងវិញទេ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ដោយស្ងៀមស្ងាត់ ។

៥- អោយសិស្សបង្ហាញចំលើយលើក្តារឆ្នួន ។

៦- ធ្វើកំនែរួមលើក្តារខៀន ។ ហៅសិស្សម្នាក់ឡើងមកសរសេរបំពេញចន្លោះទាំងនោះ ។

<u>ចំលើយ</u> : - បច្ចុប្បន្ន ឥឡូវនេះ សព្វថ្ងៃនេះ សម័យនេះ ...

- ជំនាន់ដើម កាលពីដើម ជំនាន់មុន សម័យមុន ....
- មធ្យោបាយ យានជំនិះ

ខ- <u>លំហាត់ទី ២</u>

ខាងក្រោមនេះមានកន្សោមពាក្យបួន ។ កន្សោមពាក្យនីមួយៗមានឧទាហរណ៏ប្រាំសំរាប់អោយអ្នកជ្រើសរើស ។ ក្នុងឧទាហរណ៏ទាំងប្រាំនោះ មានឧទាហរណ៏មួយខុស ។ ចំលងឧទាហរណ៏ទាំងបួនដែលត្រូវដាក់ក្នុងសៀវ- ភៅរបស់អ្នក តាមគំរូឧទាហរណ៏ខាង ក្រោម ▪

<u>ឧទាហរណ៏</u> : ផលិតផល : ស្រូវ ឆ្នាំង ពោត ល្ង ។

១- ផលិតផល :
← ស្រូវ
↑ ស្ពឺង
→ ឆ្នាំង
↓ ពោត
○ ល្ង

២- ផ្លូវគមនាគមន៏ :
← ថ្នល់

| | | |
|---|---|---|
| | ↑ | ទន្លេ |
| | → | យានជំនិះ |
| | ↓ | សមុទ្រ |
| | ० | ស្ទឹង |
| ៣- ភោគផល : | ← | កៅស៊ូ |
| | ↑ | រ៉ែត្បូង |
| | → | ចាន |
| | ↓ | ព្រៃឈើ |
| | ० | ត្រី |
| ៤- មធ្យោបាយដឹកជញ្ជូន : | ← | យន្តហោះ |
| | ↑ | កប៉ាល់ទឹក |
| | → | រថភ្លើង |
| | ↓ | ទូក |
| | ० | ផ្លូវទឹក |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀន (បើមានលទ្ធភាពលំហាត់នេះគួរសរសេរលើផ្ទាំងក្រដាសធំ) ។

២- អោយសិស្សអានលំហាត់នៅលើក្តារខៀនជាបុគ្គលដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយពាក្យសំដីរបស់គេផ្ទាល់។ មិនមែនអោយអានលំហាត់ឡើងវិញទេ។

៤- ទុកពេលគ្រប់គ្រាន់អោយសិស្សធ្វើលំហាត់ជាបុគ្គល រឺជាក្រុមពីរៗនាក់ ។

៥- ធ្វើកំនែរួមលើក្តារខៀន។ អោយសិស្សម្នាក់ឡើងមកគូសឧទាហរណ៍ដែលខុសនៅលើក្តារខៀនចោល រួចអោយសិស្សឯទៀតកែតំរូវ នៅលើសៀវភៅរៀងៗខ្លួន ។

<u>ចំលើយ</u> :

| | | | | | |
|---|---|---|---|---|---|
| ផ្លូវគមនាគមន៍ | : | ថ្នល់ | ទន្លេ | សមុទ្រ | ស្ទឹង ។ |
| ភោគផល | : | កៅស៊ូ | រ៉ែត្បូង | ព្រៃឈើ ត្រី ។ | |
| មធ្យោបាយដឹកជញ្ជូន | : | យន្តហោះ | កប៉ាល់ទឹក | រថភ្លើង | ទូក ។ |

# ផ្នែកទី ២

# ឧទាហរណ៍ព្រឹត្តិប័ត្រគរុកោសល្យ

### ការបញ្ចូលលំហាត់អំនានស្ទាត់នៅក្នុងការបង្រៀនអំនានថ្នាក់ទី ៣

ដើម្បីជាជំនួយដល់ការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ យើងខ្ញុំសូមជូនឧទាហរណ៍ពីរ អំពីមេរៀនអំនានដែល មានបញ្ចូលលំហាត់អំនានស្ទាត់ ។ លំហាត់ទាំងនេះ អាចមានប្រសិទ្ធភាព លុះត្រាតែអស់លោកធ្វើតាមការណែនាំ របស់លំហាត់នីមួយៗ ដើម្បីអភិវឌ្ឍសមត្ថភាពយល់ដឹង និងសមត្ថភាពអានរបស់សិស្ស ពុំនោះទេ លំហាត់ដដែល នេះ នឹងប្តូរទៅអភិវឌ្ឍសមត្ថភាពផ្សេងទៅវិញ ។ ដំនឹកនាំសកម្មភាពបង្រៀននេះ គឺយកតាមលំនាំនៃការបង្រៀន នៅក្នុងសៀវភៅគ្រូសុទ្ធសាធ ដោយគ្រាន់តែបញ្ចូលលំហាត់ចំនួនពីរ នៅត្រង់ចំនុចទីពីរនៃវិធីបង្រៀន (អំនាន លើកទី ១) ។

| ដំនឹកនាំមេរៀនអំនាននៅថ្នាក់ទី ៣ | សំនើដំនឹកនាំមេរៀនអំនានដើម្បីបញ្ចូលលំហាត់អំនានស្ទាត់ |
|---|---|

| | |
|---|---|
| ដែលមាននៅក្នុងសៀវភៅរបស់ក្រសួង អយក | |
| ១- សេចក្តីផ្តើម - ការស្ទាបស្ទង់បុរេពុទ្ធិ | ១- សេចក្តីផ្តើម - ការស្ទាបស្ទង់បុរេពុទ្ធិ |
| ២- អំនានដោយគ្រូ រឺដោយសិស្សពូកែម្នាក់ | ២- អំនានស្ងាត់ ( សិស្សធ្វើលំហាត់ដោយស្ងៀមស្ងាត់ជាបុគ្គល) តាមរយៈលំហាត់ទាំងនេះ សិស្សអាចយល់អត្ថបទបាន |
| ៣- ការពន្យល់ពាក្យពិបាក<br>៤- អំនានលើកទី ២ និងសំនួរត្រិះរិះស្វែងយល់ សេចក្តីលំអិតរបស់អត្ថបទ ( ផ្ទាល់មាត់)<br>៥- អំនានក្នុងក្រុម ( ដោយគោរពសញ្ញាសំព័ន្ធ )<br>៦- អភិវឌ្ឍន៍ចំនេះដឹង<br>៧- វង្វាយតំលៃ | ៣- ការពន្យល់ពាក្យពិបាក<br>៤- អំនានលើកទី ២ និងសំនួរត្រិះរិះស្វែងយល់ សេចក្តីលំអិតរបស់អត្ថបទ ( ផ្ទាល់មាត់)<br>៥- អំនានក្នុងក្រុម ( ដោយគោរពសញ្ញាសំព័ន្ធ )<br>៦- អភិវឌ្ឍន៍ចំនេះដឹង<br>៧- វង្វាយតំលៃ |

## ជំពូកទី ១

## មេរៀនទី ១

## មេសូត្រ : ❑ការរស់នៅស្អាត❑

ស.ស ទំព័រទី ៧

ស.គ ទំព័រទី ១៥ ១៦

**វត្ថុបំណង**

សិស្សមានសមត្ថភាព :

- សូត្រមេសូត្របទពាក្យប្រាំពីរបានត្រឹមត្រូវ ។
- ប្រាប់សេចក្តីលំអិត និង ខ្លឹមសារមេសូត្រ ។
- រកពាក្យជួន ។

- ចេះសំអាតខ្លួនតាមក្បួនអនាម័យ ។

**<u>សំភារៈ</u>**

- ស.ស ទំព័រទី ៧ ។

**<u>វិធីបង្រៀន</u>**

**១- <u>ការស្ទាបស្ទង់បុរេពុទ្ធិ</u>**

ក- គ្រូសួរថា ◘ ពេលក្រោកពីដំនេក និងមុនពេលហូបចំនីអាហារ តើអ្នកធ្វើដូចម្តេចខ្លះ ? ◘ ។

ខ- គ្រូអោយសិស្សម្នាក់ៗ បើកសៀវភៅរៀងៗខ្លួន ត្រង់ទំព័រទី ៧ (បើសិស្សគ្មានសៀវភៅពុម្ពគ្រប់គ្នាទេ គ្រូត្រូវចំលងមេសូត្រ ដាក់លើក្តារខៀន) ។ គ្រូណែនាំអោយសិស្សមើលរូបភាពលើទំព័រនោះ ហើយសួរសិស្សថា ◘ តើក្មេងក្នុងរូបភាពនេះធ្វើអ្វីខ្លះ ? ◘ ។ គ្រូបង្ហាញចំនងជើងមេសូត្រ រួចអោយសិស្សទាយលមើល តើមេសូត្រនេះនិយាយអំពីអ្វី ? ចំលើយសិស្សអាចខុសគ្នា តែគ្រូមិនកំនត់ត្រូវរឺខុសទេ ព្រោះជាការទស្សន៍ទាយ ។

**២- <u>លំហាត់អំនានស្ងាត់</u>**

ក- <u>លំហាត់ទី ១</u>

ចូរអានអត្ថបទមេសូត្រ ទំព័រទី ៧ សៀវភៅសិស្សដោយស្ងៀមស្ងាត់ ។

ស្រង់កន្សោមពាក្យទាំងឡាយណា ដែលបញ្ជាក់ពីការសំអាតខ្លួនប្រាណដាក់លើក្តារឆ្នួន ។

**<u>លំនាំនៃការបង្រៀន</u>**

១- ចំលងលំហាត់ដាក់លើក្តារខៀនមុនពេលចូលរៀន ។

២- អោយសិស្សអានលំហាត់ដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់អំពីសំនួមពរលំហាត់ តើគេអោយអ្នកធ្វើអ្វីខ្លះ ?

(មិនអោយសិស្សអានលំហាត់ឡើងវិញទេ) ។ បើសិស្សមិនយល់ គ្រូត្រូវពន្យល់បន្ថែម ។

៤- អោយសិស្សអានអត្ថបទមេសូត្រក្នុងសៀវភៅដោយស្ងៀមស្ងាត់ ។

៥- ទុកពេលអោយសិស្សធ្វើលំហាត់ ។

៦- អោយសិស្សសរសេរចំលើយលើក្តារឆ្នួន ។

៧- ធ្វើកំនែរួមនៅលើក្តារខៀន ។

៨- អោយសិស្សកែកំហុសខ្លួនឯងលើក្តារឆ្នួនរៀងៗខ្លួន ។

៩- អោយសិស្សអានចំលើយដែលគេបានកែត្រឹមត្រូវនៅលើក្តារខៀន ។

<u>ចំលើយ</u> : សំអាតកាយា ដុសក្អែល លាងដៃ ដុសធ្មេញ ។

ខ- <u>លំហាត់ទី ២</u>

| |
|---|
| ចូរស្រង់លេខសំនួរខាងក្រោម ភ្ជាប់ទៅនឹងចំលើយដែលត្រូវគ្នា រួចផ្ទៀងផ្ទាត់ទៅនឹងអត្ថបទ ។ សរសេរចំលើយលើក្តារឆ្នួន ។<br>១- មុនទៅសាលារៀនតើគេធ្វើអ្វីខ្លះ ? ក- បោសគ្រែ ពូកក្តារមុងខ្នើយ ដេញមូស។<br>២- មុននិងក្រោយពេលហូបអាហារ តើគេធ្វើអ្វីខ្លះ ? ខ- លាងដៃ ដុសធ្មេញ។<br>៣- មុនពេលចូលដំនេកតើគេធ្វើអ្វី ? គ- ងូតទឹកសំអាតខ្លួន ស្លៀកពាក់។<br>ឃ- ធ្វើកិច្ចការដែលគ្រូដាក់អោយ។ |

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀនមុនម៉ោង ។

២- អោយសិស្សអានលំហាត់លើក្តារខៀនដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ ដោយសំដីផ្ទាល់របស់គេ ។ មិនអោយអានលំហាត់ឡើងវិញទេ ។ គ្រូត្រូវពន្យល់បើសិស្សមិនយល់លំហាត់ ។

៤- អោយសិស្សសរសេរចំលើយលើក្តារឆ្នួនតាមគំរូនេះ :

| | |
|---|---|
| ១ | |
| ២ | |
| ៣ | |

គ្រូគូសតារាងលើក្តារខៀន សិស្សគូរលើក្តារឆ្នួន ។

៥- ទុកពេលអោយសិស្សគិតពិចារណាផ្ទួផ្ទង ។

៦- ធ្វើកំនែរួមលើក្តារខៀនដោយអោយសិស្សម្នាក់ឡើងមកបំពេញចំលើយក្នុងតារាង រួចអោយសិស្សអានសំណួរនិងចំលើយដែលត្រូវគ្នា ។

ចំលើយ :

| | |
|---|---|
| ១ | គ |
| ២ | ខ |
| ៣ | ក |

**៣ - ការពន្យល់ពាក្យពិបាក**

ក- គ្រូសួររកពាក្យពិបាក រួចសរសេរពាក្យពិបាកទាំងនោះដាក់លើក្តារខៀន ។

ខ- អោយសិស្សអាននិងពន្យល់ពាក្យពិបាកទាំងនោះជាមុនសិន ។ បន្ទាប់មកគ្រូជួយកែតំរូវប្រសិនបើចាំបាច់ ។

សុខភាព (ន) : សេចក្តីសុខ ភាពជាសុខ ។

សុវត្ថិភាព (ន) : ភាពប្រកបដោយសេចក្តីសុខ ។

ចលនា (ន) :ការកំរើក សកម្មភាព ។

អនាម័យ (ន) : ភាពគ្មានជំងឺ ។

**៤- អំណានឈើ**

ក- គ្រូសូត្រមេសូត្រ រឺអោយសិស្សម្នាក់សូត្រមេសូត្រនេះឡើងវិញ ។

ខ- គ្រូបំផុសសំនួរ ដើម្បីស្ទាបស្ទង់ការយល់ដឹង : តើមេសូត្រនេះនិយាយអំពីអ្វី ? មុនពេលទៅសាលារៀនតើគេធ្វើអ្វីខ្លះ ? មុននិងក្រោយពេលហូបអាហារ តើគេធ្វើអ្វី ? មុនពេលចូលដំនេក តើគេធ្វើដូចម្តេច ? តើគេបានធ្វើអ្វី

ខ្លះ ដើម្បីអោយមានសុខភាពល្អ ?

គ- បើពិនិត្យឃើញថា សិស្សពុំទាន់ចាប់បានខ្លឹមសារមេសូត្រនេះទេ គ្រូអោយសិស្សពីរនាក់ ទៀតសូត្រមេសូត្រនេះឡើងវិញម្តងទៀត ។

**៥- លំហាត់អានតាមក្រុម**

ក- ចែកសិស្សជាក្រុម គ្រូអោយសិស្សក្នុងក្រុមសូត្រមេសូត្រមួយឃ្លាម្នាក់ៗរហៀតដល់ចប់ ។

ខ- គ្រូតាមដានសកម្មភាពសិស្សនៅតាមក្រុម និងជួយកែលំអការធ្វើបទ រឺចង្វាក់របស់មេសូត្រអោយបានច្បាស់លាស់ និងម៉ត់ចត់ជាទីបំផុត ។

គ- គ្រូអោយសិស្សតាមជួរតុ សូត្រមេសូត្រម្តងមួយវគ្គៗ រួចគ្រូលុបពាក្យខ្លះជាបណ្តើរៗ រហូតដល់ជិតអស់ ។

**៦- ការអភិវឌ្ឍចំណេះដឹង**

ក- គ្រូអោយសិស្សតាមជួរតុរកនឹក និងបំពេញចន្លោះទាំងនោះឡើងវិញ ។ សិស្សផ្សេងទៀតចូលរួមផ្តល់មតិ ។

ខ- គ្រូហៅអោយសិស្សណាម្នាក់ឡើងសូត្រមេសូត្រទាំងមូលឡើងវិញ ។

**៧- វាយតំលៃ**

ក- គ្រូចែកសិស្សជា ៣ ក្រុម រួចអោយក្រុមនីមួយៗធ្វើលំហាត់ ខ ទំព័រទី ៨ ។

- ចូរប្រាប់លេខចំលើយណា ដែលជាខ្លឹមសារនៃវគ្គនីមួយៗ ។
- វគ្គទី ១ : រាល់ថ្ងៃ ..................... គ្រប់គ្រា ។

 ១- ការហូបអាហារមុនពេលទៅសាលារៀន ។

 ២- ការទៅសាលារៀនអោយទាន់ពេលវេលា ។

 ៣- ការសំអាតខ្លួន មុនពេលទៅសាលា ។

- វគ្គទី ២ : មុនហូប ................... មិនឈឺឡើយ ។

១- ការសំអាតដៃ និងមាត់ ។

២- ការហូបអាហារជាមួយគ្រួសារ ។

៣- ការហូបអាហារទៀងទាត់ពេល ។

- វគ្គទី ៣ : រាល់យប់ ................ សុខភាពល្អ ។

១- ការសំអាតកន្លែងដេក ។

២- ការចូលដំនេកពីព្រលប់ ។

៣- ការបោសសំអាតផ្ទះសំបែង ។

ក- អោយក្រុមទី ១ រកខ្លឹមសារសំខាន់នៃមេសូត្រនៅក្នុងវគ្គទី ១ ក្រុមទី ២ រកខ្លឹមសារ សំខាន់នៃមេសូត្រក្នុងវគ្គទី ២ ក្រុមទី ៣ រកខ្លឹមសារសំខាន់នៃមេសូត្រនៅក្នុងវគ្គទី ៣ ។ ក្រុមនីមួយៗជ្រើសរើសចំលើយ ១ ក្នុងចំនោមចំលើយ ៣ ដែលបានផ្តល់អោយ ។

ខ- តំនាងក្រុមនីមួយៗ ឡើងបង្ហាញចំលើយ ។ ក្រុមឯទៀតជាអ្នកវាយតំលៃ ។

- គ្រូសរសេរចំលើយត្រឹមត្រូវលើក្តារខៀន ។

<u>ចំលើយ</u> : វគ្គទី ១ លេខ ៣ ។ វគ្គទី ២ លេខ ១ ។ វគ្គទី ៣ លេខ ១ ។

*

*           *

## <u>ជំពូកទី ១</u>

## <u>មេរៀនទី ២</u>

## <u>អំនាន</u> : ■ចំនីអាហារទ្រទ្រង់ជីវិត■

ស.ស ទំព័រទី ១៥

ស.គ ទំព័រទី ៣៣

**<u>វត្ថុបំនង</u>**

សិស្សមានសមត្ថភាព ៖

- បង្ហាញខ្លឹមសារសំខាន់របស់អត្ថបទ ។
- បង្ហាញចំនែកថ្នាក់គំនិតទៅតាមជំពូក ។
- ប្រើប្រាស់ចំនីអាហារបានសមស្របសំរាប់ទ្រទ្រង់រាងកាយ ។

**<u>សំភារៈ</u>**

- ស.ស ទំព័រទី ១៥ ។

**<u>វិធីបង្រៀន</u>**

**១- <u>ការស្ទាបស្ទង់បុរេពុទ្ធិ</u>**

ក- គ្រូបំផុសសំនួរ ៖ តើរាល់ថ្ងៃអ្នកបរិភោគអ្វីខ្លះ ? តើចំនីអាហារទាំងនោះមានប្រយោជន៍អ្វីខ្លះចំពោះអ្នក ? គ្រូទទួលយកចំលើយទាំងឡាយរបស់សិស្ស ។

ខ- គ្រូអោយសិស្សពិនិត្យរូបភាពក្នុងសៀវភៅសិស្សទំព័រទី ១៥ ( បើសិស្សពុំមានសៀវភៅទេ គ្រូលើករូបភាពបង្ហាញ) ។ គ្រូណែនាំសិស្សសង្កេតមើលរូបភាពនៅលើទំព័រ ហើយសួរថា " តើរូបភាពនេះបង្ហាញអំពីអ្វី ?" តើអ្នកធ្លាប់បរិភោគម្ហូបអាហារអ្វីខ្លះ ?

**២- <u>លំហាត់អំនានស្ទាត់</u>**

ក- <u>លំហាត់ទី ១</u>

អានអត្ថបទស.ស ទំព័រទី ១៥ ។

ចូររកចំលើយមួយរឺច្រើន ដោយស្រង់លេខណាមួយ រឺលេខទាំងឡាយណាដែលត្រូវនឹងអត្ថបទ ។ សរសេរ

ចំលើយលើក្តារខ្នួន ។

ក- កុមារដែលបរិភោគអាហារគ្រប់ប្រភេទ ជាកុមារ ៖

១- សប្បាយចិត្ត

២- មានការល្បែតលាស់ល្អ

៣- មានជំងឺញ៉ើកញាប់

ខ- នៅក្នុងរូបភាព ក្នុងសៀវភៅសិស្សទំព័រ ១៥ ខ្ញុំឃើញ :

១- គោញីមួយ

២- ត្រី

៣- មាន់មួយ

៤- ទឹកដោះគោ

គ- គេចែកចំនីអាហារជា :

១- បួនប្រភេទ

២- ប្រាំប្រភេទ

៣- ពីរប្រភេទ

៤- បីប្រភេទ

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀនមុនម៉ោង ។

២- អោយសិស្សអានអត្ថបទក្នុងសៀវភៅទំព័រទី ១៥ ដោយស្ងៀមស្ងាត់ ដោយមិនអោយអ្នកណាម្នាក់អានលឺជាមុនឡើយ ។

៣- អោយសិស្សអានលំហាត់ដែលសរសេរនៅលើក្តារខៀនដោយស្ងៀមស្ងាត់ ។

៤- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើ មិនមែនអោយសិស្សអានលំហាត់ឡើងវិញទេ ។

៥- ពន្យល់សិស្សអំពីរបៀបឆ្លើយនឹងសំនួរ ដោយស្រង់លេខណាមួយ រឺលេខទាំងឡាយណាដែលជាចំលើយត្រូវ ។ ធ្វើលំហាត់ជាឧទាហរណ៍មួយ :

ឧទាហរណ៍ : នៅក្នុងអាហារប្រភេទទី ២ យើងឃើញ :

ក- អង្ករ

ខ- គោ

គ- គ្រាប់ពោធិ៍សាត់

ចំលើយ : （ក）

៦- ទុកពេលអោយសិស្សម្នាក់ៗធ្វើលំហាត់ ។

៧- ធ្វើកំនែរួមនៅលើក្តារខៀន ។

សំគាល់ : សំរាប់សំនួរ " គ " អាចនឹងចាំបាច់អោយសិស្សអានអត្ថបទទាំងមូលដោយស្ងាត់ស្ងៀមឡើងវិញ មុននឹងឆ្លើយ រួចទើបអោយអានលឺដើម្បីធ្វើកំនែ ។

| | | | | | |
|---|---|---|---|---|---|
| ចំលើយ : | ក | : | ២ | | |
| | ខ | : | ២ | ៣ | ៤ |
| | គ | : | ៤ | | |

ខ- លំហាត់ទី ២

ចូរអានអត្ថបទសៀវភៅសិស្សទំព័រទី ១៥ រួចញែករូបភាពទៅតាមព័ត៌មានក្នុងអត្ថបទ ។

**លំនាំនៃការបង្រៀន**

១- ចំលងលំហាត់ដាក់លើក្តារខៀនមុនម៉ោង ។

២- អោយសិស្សអានលំហាត់នៅលើក្តារខៀនដោយស្ងៀមស្ងាត់ ។ អោយសិស្សប្រាប់ពីសំនូមពរលំហាត់ តើគេអោយអ្នកធ្វើអ្វី មិនមែនអោយសិស្សអានលំហាត់នេះសាឡើងវិញទេ ប៉ុន្តែត្រូវអោយសិស្សពន្យល់មកយើងវិញតាមគំនិតដែលគេយល់ ។

៣- អោយសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ ។

៤- ទុកពេលអោយសិស្សដើម្បីឆ្លើយនឹងសំនួរ（សិស្សអាចគូរតិចៗលើរូបភាព）។

៥- ធ្វើកំនែរួមដោយផ្តើមចេញពីរូបភាព ។

ចំលើយ :



## ៣- ការពន្យល់ពាក្យពិបាក

បន្ទាប់មក អោយសិស្សប្រាប់ពាក្យពិបាក ។ គ្រូអោយសិស្សសាកល្បងពន្យល់ន័យពាក្យនោះ ។ បើសិស្សមិនអាចពន្យល់ន័យនៃពាក្យនោះបានទេ គ្រូត្រូវអាន និងពន្យល់ន័យនៃពាក្យនោះប្រាប់សិស្ស ។ គ្រូគួរប្រើរូបភាព រឺឧទាហរណ៍ រឺវត្ថុជាក់ស្តែង ដើម្បីអោយសិស្សយល់ពាក្យ ។

បរិភោគ (កិ) : ហូប ស៊ី ញាំុ ។

តុល្យភាព (ន) : ភាពថ្លឹងមើលអោយដឹងភាគស្មើគ្នា ។

ចំនីអាហារ (ន) : របស់ដែលអាចហូបបាន ។

## ៤- អំនានលឺ

ក- គ្រូអោយសិស្សម្នាក់អានអត្ថបទនេះឡើងវិញ ។

ខ- គ្រូសួរសំនួរស្ទាបស្ទង់ការយល់ដឹងរបស់សិស្ស (មើលសំនួរក្នុង ស.ស ទំព័រទី ១៦)

១- ហេតុអ្វីបានជាមនុស្សត្រូវការបរិភោគចំនីអាហារ ?

២- តើចំនីអាហារ ជាវត្ថុដូចម្តេចសំរាប់មនុស្ស ? ព្រោះអ្វី ?

៣- តើចំនីអាហារ មានប៉ុន្មានប្រភេទ ?

៤- តើប្រភេទនីមួយៗ មានអ្វីខ្លះ ?

៥- ហេតុអ្វីបានជាត្រូវបរិភោគចំនីអាហារទាំងបីប្រភេទ ?

## ៥- លំហាត់អានតាមក្រុម

ក- គ្រូចែកសិស្សជាក្រុម រួចអោយពួកគេអានអត្ថបទនោះតាមក្រុមរៀងៗខ្លួន ។ តំនាងក្រុមត្រូវជួយ និងតាមដាន អំនានរបស់សមាជិកក្រុមខ្លួន ។ បើសិស្សណាម្នាក់ (ក្នុងក្រុម) អានមិនទាន់បានល្អ រឺអានខុស មិត្តភក្តិនៅក្នុងក្រុម ជាមួយ ត្រូវជួយកែតំរូវ ។ តំនាងក្រុមត្រូវជំរុញសមាជិកក្រុមខ្លួនអោយអានបានគ្រប់គ្នា ។

ខ- សិស្សអានផ្នែកតូចៗនៃអត្ថបទនោះ ដោយអានបន្តគ្នានៅក្នុងក្រុមខ្លួន ។ សូមធ្វើយ៉ាងនេះ រហូតដល់សិស្សនៅក្នុងក្រុមបានអានគ្រប់ៗគ្នា ។

គ្រូតាមដានការអានរបស់សិស្សនៅតាមក្រុមនីមួយៗរួចជួយកែតំរូវប្រសិនបើចាំបាច់ ។

**៦- ការពិនិត្យចំនេះដឹង**

ក- គ្រូហៅសិស្សម្តងម្នាក់ៗ ( មួយចំនួន) ឡើងអានអត្ថបទទាំងមូលឡើងវិញ ។

ខ- គ្រូសួរសំនួរបន្ថែមទៀត ដើម្បីភ្ជាប់ខ្លឹមសារអត្ថបទទៅនឹងជីវភាពជាក់ស្តែងរបស់សិស្សក្នុងមូលដ្ឋាននោះ ។

**៧- វាយតំលៃ**

ក- អោយសិស្សតាមក្រុមនីមួយៗធ្វើលំហាត់ " ក " ទំព័រទី ១៦ ។

តើអត្ថបទអំនានខាងលើនេះ និយាយអំពីអ្វី ? ចូរប្រាប់លេខចំលើយមួយដែលអ្នកយល់ថាត្រឹមត្រូវ ។

១- អាហារដែលគេពុំអាចបរិភោគ ។

២- ចំនីអាហារសំរាប់ទ្រទ្រង់ជីវិតមនុស្ស ។

៣- ការចំអិននិងការថែរក្សាចំនីអាហារ ។

សិស្សតាមក្រុមពិភាក្សាគ្នារកចំលើយមួយដែលនិយាយអំពីខ្លឹមសារសំខាន់នៃអត្ថបទអំនាន ។

ខ- តំនាងក្រុមឡើងរាយការណ៍ចំលើយរបស់ក្រុមខ្លួន ។ ឯសិស្សក្រុមដទៃទៀតជួយកែលំអ រឺវិនិច្ឆ័យថាខុសរឺត្រូវ ។

គ- គ្រូណែនាំសិស្សអោយធ្វើកំនែរួមនៅលើក្តារខៀន បន្ទាប់មក ប្រមូលកិច្ចការសិស្សមកកែ និងដាក់ពិន្ទុអោយក្រុម ។

<u>ចំលើយ</u> : ល្បះទី ២

**៨- កិច្ចការផ្ទះ**

ក- សិស្សត្រូវគូសតារាងតាមលំនាំក្នុងសៀវភៅពុម្ពទំព័រទី ១៦ ត្រង់លំហាត់ "ខ" ។ បើសិស្សពុំមានសៀវភៅមើល

គ្រប់គ្នាទេនោះ គ្រូត្រូវគូសតារាងគំរូនោះលើក្តារខៀន ។

- ចូរចំលងពាក្យ រួចគូសតារាងដូចខាងក្រោម ដាក់ក្នុងសៀវភៅសរសេរអ្នក ។ ចូររៀបពាក្យទាំងនោះដាក់តាមក្រុមបន្លែ ផ្លែឈើ និងសាច់ ។

មៀន ត្រលាច ដំឡូងបារាំង ផ្លែថាវ ការ៉ុត សាច់ជ្រូក ល្ហុង ប៉េងប៉ោះ សាច់គោ ក្រូចពោធិ៍សាត់ ស្វាយ សាច់មាន់ សាច់ទា ទុរេន ភ្លៀវ ។ល។

| សាច់ | បន្លែ | ផ្លែឈើ |
|---|---|---|
| ....................................<br>.................................... | ....................................<br>.................................... | ....................................<br>.................................... |

ខ- សិស្សចំលងពាក្យទាំងអស់នៅក្នុងលំហាត់ "ខ" និងគូសតារាងតាមគំរូនៅលើក្ដារខៀន ដាក់ក្នុងសៀវភៅរៀងខ្លួន រួចរើសពាក្យដាក់តាមក្រុម សាច់ បន្លែ និងផ្លែឈើ នៅក្នុងតារាងដែលខ្លួនបានគូសរួចហើយ ។

គ- គ្រូត្រូវរំលឹកសិស្សថា " ថ្ងៃក្រោយនៅម៉ោងអំនាន គ្រូធ្វើកំនែលំហាត់នេះដាក់លើក្ដារខៀន រួចដាក់ពិន្ទុ ។"

<u>ចំលើយ</u> : បន្លែ : ត្រលាច ដំឡូងបារាំង ឆៃថាវ ការ៉ុត ល្ពៅ(ខ្ទឹម) ប៉េងប៉ោះ ។

ផ្លែឈើ : ម្នូន គ្រូចពោធិ៍សាត់ ស្វាយ ទុរេន ត្បៀវ ។

សាច់ : សាច់ជ្រូក សាច់គោ សាច់មាន់ សាច់ទា ។

*

* *